# សៀវភៅសង្ខេប
# ស្តីពី
# ការណែនាំពីការអនុវត្តន៍វារីវប្បកម្មល្អ









## សម្រាប់កសិករ

## (ផលិតកូនត្រី និងចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ)

រៀបចំឡើងដោយផ្អែកលើបទពិសោធន៍គម្រោងអភិវឌ្ឍន៍វារីវប្បកម្មនៃនាយកដ្ឋាន
អភិវឌ្ឍន៍វារីវប្បកម្ម រដ្ឋបាលផលផលសហការជាមួយអង្គការអាយដា
នៅខេត្តគោលដៅទាំង៤របស់គម្រោងគឺ
ខេត្តក្រចេះ ស្ទឹងត្រែង រតនៈគិរី និងខេត្តមណ្ឌលគិរី

# អារម្ភកថា

សៀវភៅសង្ខេបនេះបានផ្តួចផ្តើមរៀបចំដោយអង្គការ អាយដា (AIDA, Ayuda Intercambio y Desarrollo, through the project: "Addressing gender issues and promoting greater access to quality fish production for sustainable development of the aquaculture sector in Cambodia, code: 10-PR1-0409") ដែលបានបង្ហាញពីការអនុវត្តបច្ចេកទេសវារីវប្បកម្មល្អ ដោយបានបញ្ជាក់ជាចំនុចសំខាន់ៗនៃការគ្រប់គ្រងវារីវប្បកម្មល្អដែលមាន
លក្ខណៈសមស្របនិងអាចអនុវត្តន៍បានដោយកសិករ សំដៅជួយដល់អង្គការនានាដែលកំពុងផ្សព្វផ្សាយ និងជម្រុញការអនុវត្តវារីវប្បកម្មល្អ ជួយផ្សព្វផ្សាយបន្តសម្រាប់ការអភិវឌ្ឍវិស័យវារីវប្បកម្មក្នុងប្រទេសកម្ពុជា។ គ្រប់ចំនុចក្នុងសៀវភៅនេះ ជាធនធានចំណេះដឹងមូលដ្ឋានអំពីបច្ចេកទេសវារីវប្បកម្មសម្រាប់កសិករផលិតកូនត្រី និងចិញ្ចឹមត្រី យកទៅអនុវត្តឱ្យបានល្អនិងទទួលបានជោគជ័យ ដោយធ្វើការសិក្សាស្វែងយល់ពីគ្រប់ចំណុចការអនុវត្តល្អ បញ្ហាជួបប្រទះ និងដំណោះស្រាយសម្រាប់ធ្វើការកែលម្អការអនុវត្តបច្ចេកទេសវារីវប្បកម្ម និងការគ្រប់គ្រង។ ទោះបីជាយ៉ាងណាក៏ដោយ អង្គការអាយដាសង្ឃឹមថា តាមរយៈសៀវភៅនេះកសិករនឹងទទួលបានចំណេះដឹងបន្ថែមដែលបានណែនាំពីការអនុវត្តបច្ចេកទេសឬការគ្រប់គ្រងវារីវប្បកម្មល្អ ប្រកបដោយគុណភាព ដោយអាស្រ័យនឹងការយកចិត្តទុកដាក់អនុវត្តផ្ទាល់របស់កសិករ ធនធានរបស់កសិករដែលមាននិងអ្នកផ្តល់សេវាកម្មបច្ចេកទេសជួយផ្សព្វផ្សាយបន្តពីការអនុវត្តវារីវប្បកម្មល្អនេះទៅតំបន់ដទៃទៀត។

សៀវភៅសង្ខេបនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើបទពិសោធន៍ជាក់ស្តែងរបស់គម្រោងអភិវឌ្ឍន៍វារីវប្បកម្មនៅតំបន់ភូមិភាគឥសាន្តនៃប្រទេសកម្ពុជា ក្នុងខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនៈគីរី និងខេត្តមណ្ឌលគិរី អនុវត្តដោយនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្មនៃរដ្ឋបាលជលផលសហការជាមួយអង្គការអាយដា AIDA និងឧបត្ថម្ភថវិកាដោយអេស៊ីត AECID។ សៀវភៅសង្ខេបនេះ ត្រូវបានរៀបចំឡើងដោយយកចិត្តទុកដាក់លើច្បាប់ក្នុងតំបន់របស់អង្គការហ្វាវ ***FAO [CAC/RCP 1-1969, Rev. 3 (1997)]*** និងច្បាប់ការអនុវត្តប្រកបដោយភាពទទួលខុសត្រូវក្នុងវិស័យជលផលនៃប្រទេសកម្ពុជា (គម្រោងផែនការយុទ្ធសាស្ត្រវិស័យជលផលរយៈពេល១០ឆ្នាំ, CAMCODE-SPF 2010-2019) ផងដែរ។

# សេចក្តីថ្លែងអំណរគុណ

ការចងក្រងសៀវភៅនេះបានដោយមានការចូលរួមផ្តល់យោបល់ពីមន្ត្រីនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម និងពីមន្ត្រីខណ្ឌរដ្ឋបាលជលផលនៃរដ្ឋបាលជលផលខេត្តក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី និងខេត្តរតនៈគិរី។ សូមថ្លែងអំណរគុណជាពិសេសជូនដល់ លោក ហាវ វិសិដ្ឋ ប្រធាននាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម និងលោក ជិន ដា អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម ដែលបានជួយជ្រោមជ្រែងនិងសម្របសម្រួលដ៏ល្អក្នុងការរៀបចំសៀវភៅនេះឡើង។

ម្យ៉ាងទៀតសូមថ្លែងអំណរគុណជាពិសេសដល់ប្រជាជន រដ្ឋាភិបាលប្រទេសអេស្ប៉ាញ និងអង្គការអេស៊ីដ (AECID) តាមរយៈអង្គការអាយដា (AIDA) ដែលបានផ្តល់មូលនិធិជួយដល់ការអភិវឌ្ឍន៍វារីវប្បកម្មនៅកម្ពុជា។

# សង្ខេបមាតិកាអត្ថបទ

## ផ្នែកទី១៖ ការផលិតកូនត្រីពូជ

1.1. ការរៀបចំផែនការ និងប្លង់កសិដ្ឋាន ...... 6
1.2. ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ...... 7
1.3. ការកំណត់ទុនវិនិយោគ ...... 9
1.4. ការអនុវត្តបច្ចេកទេស គ្រប់គ្រងមេពូជ សេនេទិច និងការបង្កាត់ភ្ញាស់ ...... 9
1.5. ការគ្រប់គ្រងមេបាពូជ (មុនពេលបង្កាត់និងក្រោយពេលបង្កាត់) ...... 11
1.6. អ័រម៉ូន ថ្នាំ និងឱសថបុរាណ ...... 12
1.7. ពូជត្រី និងតម្រូវការទីផ្សារ ...... 13
1.8. ការបំប៉នកូនត្រី(បច្ចេទេស ការគ្រប់គ្រង ពេលវេលា) ...... 14
1.9. ការគ្រប់គ្រងចំណីកូនត្រី និងការផ្តល់ចំណី ...... 16
1.10. ការគ្រប់គ្រងគុណភាពទឹក (ការត្រួតពិនិត្យ និងវិធីសាស្រ្តកែលម្អ) ...... 17
1.11. ធាតុគីមីសម្រាប់ស្រះត្រី ...... 18
1.12. ជីសរីរាង្គ ...... 18
1.13. ជីគីមី ...... 19
1.14. ការថែទុកដាក់កូនត្រី ដើម្បីវេចខ្ចប់ និងដឹកជញ្ជូន ...... 20
1.15. ការថែទាំនិងប្រើប្រាស់ឧបករណ៍ និងសម្ភារៈ ...... 22

## ផ្នែកទី២៖ ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ

2.1. ការជ្រើសរើសទីតាំងស្រះ និងជីកស្រះ ...... 23
2.2. ការសាងសង់ស្រះ នឹងភ្លឺស្រះ ...... 24
2.3. ការជ្រើសរើសកូនត្រីដាក់ចិញ្ចឹម ...... 25
2.4. វិធានការការពារត្រីកាច និងទឹកជំនន់ ...... 26

2.5. វិធានការ ការពារការហូរចូលធាតុគីមីនិងថ្នាំពុល ..... 27
2.6. ការគ្រប់គ្រងគុណភាពទឹកស្រះ ..... 27
2.7. កត្តាដែលចូលរួមដល់ការរក្សាគុណភាពទឹកល្អ ..... 29
2.8. កត្តាដែលជះឥទ្ធិពលដល់ការលូតលាស់ និងអត្រារស់ខ្ពស់ ..... 30
2.9. ចំណីផ្សំរៀបចំដោយកសិករ ..... 31
2.10. ចំណីគ្រាប់ និងការផ្តល់ចំណី ..... 32
2.11. ការគ្រប់គ្រងចំណី និងរក្សាទុកចំណី(ចំណីផ្សំ) ..... 33
2.12. ការប្រមូលផលត្រី ..... 33
2.13. ការទុកដាក់ផលិតផល ដឹកជញ្ជូន និងកែច្នៃ ..... 34
2.14. ការត្រៀមដាក់ត្រីចិញ្ចឹម នៅឆ្នាំក្រោយ ..... 35

# ផ្នែកទី១៖ ការផលិតកូនត្រីពូជ

## 1.1. ការរៀបចំផែនការ និងប្លង់កសិដ្ឋាន

### 1.1.1. *ការអនុវត្តល្អ*

**ការរៀបចំផែនការ៖**

- ពេលចាប់ផ្តើមដំបូង ត្រូវប៉ាន់ប្រមាណពីទំហំកសិដ្ឋាន ដែលមានជាក់ស្តែងតាមលក្ខណៈសាមញ្ញ
- រៀបចំគម្រោងសាងសង់អាងបង្កាត់ ភ្ញាស់ ស្រះបំប៉ន តាមបច្ចេកទេស
- រៀបចំផែនការផលិតកម្មនិងផែនការពង្រីកកសិដ្ឋានដើម្បីបង្កើនផលិតកម្មឆ្លើយតបនឹងតម្រូវការទីផ្សារ ទាំងបរិមាណ និងគុណភាព)
- គិតគូរពីកំលាំងពលកម្មដែលមានក្នុងគ្រួសារ ឱ្យមានគ្រប់គ្រាន់
- សមាជិកក្នុងគ្រួសារត្រូវមានការយល់ដឹងពីបច្ចេកទេសគ្រប់ដំណើរការផលិតកម្មផលិតកូនត្រី
- កំណត់ការប៉ាន់ប្រមាណតំលៃ និងធនធានកសិដ្ឋានដែលត្រូវសាងសង់តាមលក្ខណៈបច្ចេកទេសល្អ។

**ការរៀបចំប្លង់កសិដ្ឋាន៖** គួររៀបចំកសិដ្ឋានផលិតកូនត្រីតាមលក្ខណៈដូចខាងក្រោម៖

- នៅជិតប្រភពទឹកអាចផ្គត់ផ្គង់ទឹកបានពេញមួយឆ្នាំ ឬមានទឹកយ៉ាងតិច ៦ខែ
- នៅជិតផ្ទះងាយស្រួលគ្រប់គ្រង
- ទីតាំងមិនលិចទឹក មានផ្ទៃដីធំទូលាយ និងជាប្រភេទដីមិនជ្រាបទឹក
- មានផ្លូវចេញ ចូលស្រួលដឹកជញ្ជូនកូនត្រី
- ជិតទីផ្សារផ្គត់ផ្គង់កូនត្រី
- និងទីតាំងកសិដ្ឋានត្រូវមានឈ្មោះយីហោផ្សព្វផ្សាយ។

### 1.1.2. *ការអនុវត្តមិនបានល្អ*

**ការរៀបចំផែនការ៖**

- មិនទាន់បានរៀបចំផែនការផលិតកូនត្រីពូជ ឲ្យឆ្លើយតបតាមពេលវេលា និងតម្រូវការទីផ្សារ
- មានទាន់មានទិន្នន័យគ្រប់គ្រាន់អំពីតម្រូវការ និងការផ្គត់ផ្គង់ទីផ្សារកូនត្រីពូជ (តាមតម្រូវការទាំងបរិមាណ ប្រភេទនិងគុណភាព)

**ការរៀបចំប្លង់កសិដ្ឋាន៖**

- មិនទាន់មានប្លង់ស្រះនិងប្លង់កសិដ្ឋានត្រឹមត្រូវតាមបច្ចេកទេសទៅតាមសណ្ឋានដីដែលមានជាក់ស្តែង
- ទីតាំងផលិតកូនត្រីពូជមិនមានទឹកផ្គត់ផ្គង់ផលិតកម្មគ្រប់គ្រាន់នៅរដូវប្រាំង
- ទីតាំងមិនមានសន្តិសុខ និងសុវត្ថិភាព ដូចជាមានលិចទឹក និងចោរលួច។

1.1.3. *ដំណោះស្រាយ*

**ការរៀបចំផែនការ៖**

- ចងបណ្ដាញកសិករផលិតកូនត្រី ដើម្បីបង្កើនការងារផលិតកម្មនិងលក់កូនត្រី ទាក់ទងអតិថិជន អង្គការនានា និងក្រុមកសិករចិញ្ចឹមត្រី ឬកសិករដែលមកទិញត្រី ដើម្បីសួរនាំព័ត៌មានពីទីផ្សារកូនត្រី
- ទិញត្រីមេបាពូជពីធម្មជាតិ និងត្រីប្រភេទក្រៅស្រុកល្អៗយកមកថែបំប៉នបន្ថែម
- មន្ត្រីជំនាញបានចុះជួយរៀបចំ និងផ្ដល់ប្រឹក្សាបន្ថែម។

**ការរៀបចំប្លង់កសិដ្ឋាន៖**

- បានរៀបចំប្លង់កែសម្រួលស្រះ និងជីកស្រះបន្ថែម
- ធ្វើរបងការពារកសិដ្ឋាន។

**សំនូមពរសម្រាប់ដោះស្រាយបន្ត៖**

- ពន្យល់កសិករឲ្យជីកស្រះតាមបច្ចេកទេស ដោយជីកស្រះឱ្យមានជម្រៅ និងជើងទេរឲ្យបានសមស្រប តាមប្រភេទដី
- រៀបចំប្លង់កសិដ្ឋាន និងជំរុញលើកទឹកចិត្តកសិករឱ្យរៀនសូត្រពីប្លង់កសិដ្ឋានសមស្របតាមបច្ចេកទេស ដោយផ្អែកលើផ្ទៃដីដែលកសិករមានស្រាប់
- ផ្ដល់យោបល់ និងលើកទឹកចិត្តឲ្យកសិករជីកស្រះធំសម្រាប់ដំកល់ទឹក
- បន្តបង្កើនការផលិតកូនត្រីពូជទាំងបរិមាណ និងគុណភាព
- ជួយបង្កើនស្មារតីទទួលខុសត្រូវការងារផលិតកូនត្រីរបស់សមាជិកគ្រួសារ។

## 1.2. ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ

1.2.1. *ការអនុវត្តល្អ*

**ការរៀបចំប្លង់កសិដ្ឋាន៖**

- បានរៀបចំប្លង់កសិដ្ឋាន ដូចជាទីតាំងស្រះដំកល់ទឹក អាងបង្កាត់ភ្ញាស់ ស្រះបំប៉នកូនត្រីម្រៀ និងស្រះមេពូជនៅជិតផ្ទះ
- ទីតាំងកសិដ្ឋានក្បែរប្រភពទឹក មានប្រព័ន្ធបង្ហូរទឹកចេញចូល មានប្រឡាយព័ទ្ធជុំវិញកសិដ្ឋាន
- ការងារសាងសង់អាងដំកល់ទឹកបានរឹងមាំល្អតាមបច្ចេកទេស និងដាក់តម្រងទឹកច្រោះ
- សាងសង់អាងបង្កាត់ភ្ញាស់តាមបច្ចេកទេស និងសន្សំសំចៃ (ទឹក ថវិកា...)
- កសិករមានអាងដំកល់ទឹក និងស្រះស្តុកទឹក ដែលអាចផលិតកូនត្រីបាន និងមានអាងបំប៉នកូនត្រី
- មានស្រះទំហំសមស្របសម្រាប់ដាក់ត្រីមេបាពូជ និងត្រូវមានទឹកគ្រប់គ្រាន់
- មានប្រព័ន្ធបញ្ចេញបញ្ចូលទឹកពីស្រះមេពូជ ស្រះបំប៉ន និងកំណត់នីវ៉ូទឹកស្រះបានសមស្រប
- ការថែទាំ ជួសជុលអាងទឹក អាងបង្កាត់ អាងភ្ញាស់ដោយត្រូវលាងសំអាត និងជួសជុលមុនប្រើប្រាស់
- ការគ្រប់គ្រងថែរក្សាឧបករណ៍សម្ភារៈក្រោយពេលប្រើប្រាស់ និងពេលផុតរដូវប្រើប្រាស់។

1.2.2. *ការអនុវត្តមិនបានល្អ*

**ការរៀបចំប្លង់កសិដ្ឋាន៖**

- មិនទាន់មានកន្លែងច្រោះទឹកចូល និងទឹកចេញ សម្រាប់ដំណើរការផលិត
- គ្មានប្រព័ន្ធចម្រោះប្រើទឹកឡើងវិញ
- អាងទឹកមិនទាន់រៀបប្រព័ន្ធផ្លូវទឹកចេញ
- ប្រព័ន្ធរំដោះទឹកជំនន់ មិនទាន់រៀបចំបានត្រឹមត្រូវ និងសមស្របតាមបច្ចេកទេស
- កសិដ្ឋានមិនមានប្រភពទឹកគ្រប់គ្រាន់
- ស្រះដំកល់ទឹកមានទំហំតូច មិនសមស្របតាមបច្ចេកទេស
- បាតស្រះមិនបានស្មើ ឬជម្រាល មានថ្មធំៗនៅបាតស្រះ
- សាងសង់ស្រះត្រីមេបាពូជមានទំហំតូច និងមានចំនួនតិច
- អាងបំប៉នកូនត្រីម្យៅមិនគ្រប់គ្រាន់សម្រាប់សង្គ្រោះកូនត្រីនៅពេលខ្វះទឹក ឬពេលមានទឹកជំនន់ និងសម្រាប់ដាក់កូនត្រីសម្រាប់លក់ ។

1.2.3. *ដំណោះស្រាយ*

- ប្រើស្បៃពីរជាន់ច្រោះសត្វល្អិត និងកំទេចកំទី
- លើកទំនប់ព័ទ្ធជុំវិញកសិដ្ឋាន តទុយោបង្ហូរទឹកចេញចូល និងព័ទ្ធស្បៃជុំវិញកសិដ្ឋានឬស្រះ
- ជីកអណ្តូងទឹកជំនួយ និងជីកស្រះដំកល់ទឹកបន្ថែម
- ជីកស្រះថ្មី ឬពង្រីកស្រះបន្ថែមសម្រាប់ថែបំប៉នកូនត្រី និងត្រីមេបាពូជ
- រៀបចំប្រព័ន្ធភ្លឺស្រះ និងធ្វើជើងទេរស្រះឱ្យសមស្របតាមបច្ចេកទេស
- ធ្វើដំបូលគ្របអាងដំកល់ទឹកនិងអាងភ្ញាស់បង្កាត់
- បន្តជំរុញកសិករសាងសង់អាងបំប៉នកូនត្រីម្យៅ។

**សំនូមពរដោះស្រាយបន្ទះ**

- កែលម្អរៀបចំប្លង់កសិដ្ឋានតាមបច្ចេកទេស
- រៀបចំអាងចម្រោះតាមបច្ចេកទេស ឬប្រព័ន្ធអាងចម្រោះប្រើប្រាស់ទឹកឡើងវិញ
- រៀបប្រព័ន្ធទឹកចូល និងចេញ
- លើកភ្លឺឲ្យបានខ្ពស់ និងជីកប្រឡាយរំដោះទឹកជំនន់/ បន្ថែមទុយោបង្ហូរទឹកចេញ
- រៀបចំប្រព័ន្ធបង្ហូរទឹកចូល ដោយកាត់បន្ថយការបូមទឹក
- ណែនាំនិងជំរុញកសិករឲ្យសន្សំថវិកាសម្រាប់ជីកស្រះបន្ថែម
- មន្ត្រីជំនាញចុះជួយរៀបចំប្រព័ន្ធចម្រោះទឹក ដល់កសិករ។

## 1.3. ការកំណត់ទុនវិនិយោគ

### 1.3.1. *ការអនុវត្តល្អ*

- ប៉ាន់ប្រមាណថវិកាសម្រាប់សាងសង់អាងបង្កាត់ ភ្ញាស់ ជីកស្រះបន្ថែម ទិញត្រីមេពូជ
- បានកសាងផែនការទិញចំណី ហាប៉ា និងកត់ត្រាទិន្នន័យផ្សេងៗ ឲ្យដឹងពីចំណូលនិងចំណាយក្នុងផលិតកម្ម
- កំណត់ទុនវិនិយោគក្នុងការបង្កើតកសិដ្ឋាន (ឧទាហរណ៍ ទុនបដិភាគជាមួយគំរោង)

### 1.3.2. *ការអនុវត្តមិនបានល្អ*

- មិនទាន់មានជំនាញគិតដល់ការកំណត់ទុនសម្រាប់ទិញសម្ភារៈ ជីកស្រះ និងទុនសម្រាប់ដំណើរការផលិតឲ្យបានច្បាស់លាស់នៅឡើយ
- កសិករខ្លះខ្វះថវិកាសាងសង់អាងបង្កាត់ភ្ញាស់ និងជីកស្រះបន្ថែម
- ខ្វះទុនទិញសម្ភារៈសម្រាប់ដំណើរការបង្កាត់ ទិញចំណីសម្រាប់បំប៉នត្រីមេបាពូជ ក៏ដូចជាបំប៉នកូនត្រីម្សៅ និងកូនត្រីពូជ ។ល។

### 1.3.3. *ដំណោះស្រាយ*

- បានទិញម៉ាស៊ីនបូមទឹក ទិញអរម៉ូនជាដើម
- មន្ត្រីជំនាញបានពិភាក្សាជាមួយកសិករអំពីថវិការត្រូវចំណាយ។

**សំនូមពរដោះស្រាយបន្ត**

- បន្តពិភាក្សាជាមួយកសិករ អំពីការត្រៀមថវិកាសម្រាប់ដំណើរការផលិតកូនត្រីក្នុងមួយឆ្នាំម្តង
- ណែនាំកសិករឲ្យរៀបចំបញ្ជីចំណូល ចំណាយឲ្យត្រឹមត្រូវ និងជាក់លាក់
- បណ្តុះបណ្តាលកសិករពីវិធីសាស្ត្រផ្សំចំណីពីវត្ថុធាតុដើមដែលមានក្នុងមូលដ្ឋាន និងរបៀបសន្សំទុនសម្រាប់ជីកស្រះថ្មី និងទិញមេពូជបន្ថែម។

## 1.4. ការអនុវត្តបច្ចេកទេស គ្រប់គ្រងមេពូជ សេនេទិច និងបង្កាត់ភ្ញាស់

### 1.4.1. *ការអនុវត្តល្អ*

- មេពូជមានគ្រប់គ្រាន់សម្រាប់ដំណើរការផលិតកម្ម តាមកសិដ្ឋានរៀងៗខ្លួន និងត្រូវផ្លាស់ប្តូរមេបាពូជក្នុងផលិតកម្មឱ្យបានរៀងរាល់ ២ឆ្នាំម្តង
- ការអនុវត្តការពារកុំឱ្យមានជំងឺកើតឡើង
- ត្រួតពិនិត្យជំងឺ ស្នាមរបួស និងចេះព្យាបាលត្រីដោយត្រាំទឹកអំបិល និងប្រើអ៊ីអឹម ឬ អ៊ីអ៊ីចអឹម
- ការវេចខ្ចប់ត្រីមេបា កូនត្រីពូជ និងដឹកជញ្ជូនអនុវត្តតាមបច្ចេកទេស
- កសិករខ្លះបានផ្តល់ចំណីឱ្យមានកំរិតប្រូតេអ៊ីនសមស្រប និងមានបរិមាណគ្រប់គ្រាន់
- កែលម្អគុណភាពទឹកឱ្យបានល្អជាប់ជាប្រចាំ ដោយប្រើជីធម្មជាតិ (មិនប្រើជីគីមី) អ៊ីអឹម ឬអ៊ី អ៊ិចអឹម

- បង្កាត់ភ្ញាស់តាមបច្ចេកទេស របៀបលាយថ្នាំ ប្រើថ្នាំ ប្រើចរន្តទឹកវិល ឬខ្យល់ រៀបចំសំបុកឱ្យមានអនាម័យ
- ជ្រើសរើសត្រីមេបាពូជដែលមានគុណភាពល្អ ពេញវ័យ មានស្ពែមនិងពងទុំល្អ មកបង្កាត់ ភ្ញាស់
- ថែបំប៉នត្រីមេបាពូជឱ្យមានគុណភាពល្អ មុនពេលយកមកបង្កាត់ ភ្ញាស់
- មុនធ្វើការបង្កាត់ភ្ញាស់ ត្រូវរៀបចំសំអាតអាងបង្កាត់ភ្ញាស់ឱ្យបានល្អ ត្រៀមទឹកស្អាតគ្រប់គ្រាន់ សម្រាប់បង្កាត់ភ្ញាស់ត្រី។

### 1.4.2. *ការអនុវត្តមិនបានល្អ*

- មិនទាន់បានរៀបចំត្រីមេបាពូជ ឬបែងចែកត្រីមេបាពូជតាមជំនាន់ ឧទាហរណ៍ការបង្កាត់ត្រីពេលខ្លះយកត្រីមេបា បង្កាត់ជាមួយកូនជំនាន់ក្រោយ
- បំប៉នត្រីមេបាពូជញី ឈ្មោលចូលគ្នាក្នុងស្រះតែមួយ
- កសិករខ្លះបំប៉នត្រីមេបាពូជមិនបានល្អ ដោយខ្វះថវិកាទិញចំណីមានគុណភាពមកបំប៉ន និងចំណីផ្តល់ឱ្យត្រីមិនបានគ្រប់គ្រាន់
- ត្រីមេបាពូជមានគុណភាពមិនល្អ
- កសិករផលិតកូនត្រីពូជគ្មានគុណភាពល្អ
- ខ្វះអនាម័យក្នុងដំណើរការផលិតកូនត្រី (មិនបានសំអាតឧបករណ៍សម្ភារៈ ត្រីមេបាពូជមានគុណភាពមិនល្អ និងការទុកដាក់សម្ភារៈមិនបានត្រឹមត្រូវតាមបច្ចកទេស)
- ការប្រើថ្នាំអង់ទីប៊ីយូទិក មិនទាន់បានត្រឹមត្រូវតាមកម្រិតស្តង់ដា តែត្រីជាសះស្បើយពីជំងឺ(ដំបៅ) មន្ត្រីផ្សព្វផ្សាយជលផលខេត្ត មិនទាន់យល់ពីបញ្ហាការប្រើថ្នាំនេះផងដែរ
- កសិករយល់ដឹងពីសេនេទិចនៅមានកំរិត និងមិនមានការគ្រប់គ្រងពូជ ត្រីបានល្អតាមបច្ចេកទេស
- កសិករមិនទាន់ចេះច្បាស់អំពីបច្ចេកទេសបង្កាត់ភ្ញាស់ ប្រភេទត្រីមួយចំនួន ដូចជា ត្រីកាបស ត្រីអណ្តែង ត្រីប្រា ជាដើម។

### 1.4.3. *ដំណោះស្រាយ*

- បានចាប់ផ្តើម បែងចែកត្រីមេបាពូជ ញី ឈ្មោលថែបំប៉នដាច់ដោយឡែកពីគ្នា
- កសិករខ្លះបានសំអាតអាងដំកល់ទឹក និងអាងបង្កាត់ភ្ញាស់តិចតួច។

### សំនូមពរដោះស្រាយបន្ត

- ផ្សព្វផ្សាយដល់កសិករឲ្យចេះផ្លាស់ប្តូរ និងរក្សាទុកត្រីមេបាពូជល្អៗទៅតាមជំនាន់ តាមបច្ចេកទេស
- ផ្សព្វផ្សាយដល់កសិករឲ្យចេះប្រកាន់ភ្ជាប់ការអនុវត្តអនាម័យល្អនៅគ្រប់ពេលដំណើរការផលិតកម្ម ដូចជាការប្រើប្រាស់សម្ភារៈ ជ្រើសរើសត្រីមេបាពូជដែលមានគុណភាពល្អមកបំប៉ន និងបង្កាត់ភ្ញាស់
- ផ្តល់វគ្គបណ្តុះបណ្តាលដល់កសិករ និងមន្ត្រី អំពីបច្ចេកទេសការប្រើប្រាស់ថ្នាំសារធាតុគីមី និងបច្ចេកទេសថែទាំ ដើម្បីសុវត្ថិភាពស្បៀង

- ជម្រុញឲ្យកសិករផលិតកូនត្រីឲ្យបានច្រើន ដោយផ្ដល់បច្ចេកទេសបន្ថែម ពង្រីកទំហំផលិតកម្ម តាមលទ្ធភាពកសិករ
- ថែបំប៉នត្រីមេបាពូជញី ឈ្មោល ក្នុងស្រះដាច់ដោយឡែកពីគ្នា
- ណែនាំកសិករត្រូវផ្លាស់ប្ដូរពូជត្រីចាស់ចេញ ដោយយកពូជថ្មីពីធម្មជាតិ រឺពីកន្លែងផ្សេងទៀត ជៀសវាងត្រីមេបាពូជជាន់ឈាម
- ផ្ដល់ចំណេះដឹងបច្ចេកទេសបន្ថែមអំពី ការបង្កាត់ភ្ញាស់ត្រីអណ្ដែង និងត្រីកាបស ដោយការអនុវត្តជាក់ស្ដែង។

# 1.5. ការគ្រប់គ្រងត្រីមេបាពូជ (មុនពេលបង្កាត់និងក្រោយពេលបង្កាត់)

## 1.5.1. *ការអនុវត្តល្អ*

- រៀបចំស្រះបំប៉នត្រីមេបាពូជឱ្យបានល្អ ដោយបង្កើនចំណីធម្មជាតិឱ្យមានសម្បូរក្នុងស្រះ
- រៀបចំស្រះពីរសម្រាប់ដាក់ត្រីមេបាពូជដែលបានបង្កាត់រួច ឱ្យនៅដាច់ដោយឡែកពីគ្នា
- ជ្រើសរើសត្រីមេបាពូជដែលមានគុណភាពល្អមកបំប៉ន ដោយផ្ដល់ចំណីបំប៉នដែលមានគុណភាពល្អ
- រៀបចំសំអាតឧបករណ៍ សម្ភារៈមុន និងក្រោយពេលបង្កាត់ភ្ញាស់ត្រីរួច
- បង្កាត់ភ្ញាស់តាមបច្ចេកទេស (ការលាយថ្នាំ ប្រើថ្នាំ ប្រើទឹកវិល ឬខ្យល់ រៀបសំបុក ។ល។)
- លាងសម្អាតត្រីមេបាពូជក្រោយពេលបង្កាត់ទម្លាក់ពងរួច មិនឲ្យមានការឆ្លងជំងឺឬប៉ារ៉ាស៊ីត
- បំប៉នត្រីមេបាពូជមានដង់ស៊ីតេសមស្រប និងរយៈពេលយ៉ាងតិច២ទៅ៣ខែមុនយកទៅបង្កាត់ភ្ញាស់
- លាងសំអាតអាងដំកល់ទឹក អាងបង្កាត់ភ្ញាស់ ត្រៀមទឹកគ្រប់គ្រាន់ សាកល្បងប្រព័ន្ធទុយោ ត្រៀមស្បៃគ្របមេបាពូជ ត្រៀមសំបុកសម្រាប់ត្រីពង លាយអ័រម៉ូន ត្រៀមម្ជុលសឺរ៉ាំង កន្សែងជូត ។ល។
- យកត្រីមេបាពូជញី ឈ្មោលដែលជ្រើសរើសរួចមកដាក់ផ្សាំក្នុងអាងពីរផ្សេងគ្នា ដើម្បីងាយស្រួលក្នុងការចាប់ចាក់អ័រម៉ូន
- ផ្ដល់ចំណីបរិមាណសមស្រប (ប្រភេទចំណីបំប៉នមិនសំបូរខ្លាញ់ និងឲ្យពពួកបន្លែស្រស់...)។
- អូសចាប់ត្រីមេបាពូជដោយប្រុងប្រយ័ត្ន ដើម្បីកុំឱ្យត្រីមានរបួស និងខូចគុណភាព
- កសិករបានតាមដានការលូតលាស់ និងជំងឺត្រីមេពូជ។

## 1.5.2. *ការអនុវត្តមិនបានល្អ*

- មិនដឹងជំនាន់ត្រីមេបាពូជច្បាស់លាស់ ការបង្កាត់ពេលខ្លះយកមេបា បង្កាត់ជាមួយកូន
- មិនបានសម្អាតស្រះបំប៉នត្រីមេបាពូជមុនពេលបង្កាត់ដោយកសិករខ្សត់ទឹក មិនអាចបូមចេញបាន
- បំប៉នត្រីមេបាពូជមិនបានល្អ មិនបានបែងចែកមេបាពូជឲ្យនៅដាច់ពីរគ្នា (ព្រោះខ្វះស្រះ ខ្វះថវិកាទិញចំណីមានគុណភាព) ដែលបណ្ដាលឲ្យការត្រីមេបាពូជមានគុណភាពមិនល្អ
- កសិករផលិតខ្លះមិនទាន់មានជំនាញបច្ចេកទេសបង្កាត់ភ្ញាស់ប្រភេទត្រីកាបស កាបឥណ្ឌា អណ្ដែង ត្រីប្រា ត្រីក្រាញ់...

- ផ្តល់ចំណីមានបរិមាណ និងគុណភាពមិនគ្រប់គ្រាន់
- ជម្រៅទឹកស្រះជ្រៅពេក ដាក់បរិមាណត្រីមេបាពូជបំប៉នច្រើនពេក បណ្តាលឲ្យស្រះខ្វះចំណីធម្មជាតិ ខ្វះខ្យល់អុកស៊ីសែន
- ទឹកស្រះរីងរាក់ពេក ពិសេសនៅរដូវប្រាំង
- ផ្តល់ចំណីត្រីមិនបានទៀងទាត់ និងមិនគ្រប់គ្រាន់ ទាំងបរិមាណ និងគុណភាព។

### 1.5.3. *ដំណោះស្រាយ*

- កសិករធ្វើបានតិចតួច ដូចជាការសំអាតអាងដំកល់ទឹក និងអាងបង្កាត់ភ្ញាស់
- សម្អាតស្រះបំប៉នបានខ្លះដូចជាបានបាចកំបោរ ស្ទូចចាប់កង្កែប និងស្ទូចត្រីកាចចេញ
- បានកែលំអ និងផ្តល់ចំណីដែលមានសារជាតុចិញ្ចឹមគ្រប់គ្រាន់
- ទិញត្រីមេបាពូជពីធម្មជាតិមកបំប៉នទុកបង្កាត់
- កសិករបង្កើនការចិញ្ចឹមត្រីទុកធ្វើពូជដោយខ្លួនឯង។

**សំនូមពរដោះស្រាយបន្ត**

- ជីកស្រះដំកល់ទឹក សម្រាប់ផ្គត់ផ្គង់ទឹក ពិសេសនៅរដូវប្រាំង
- ណែនាំកសិករឱ្យយកចិត្តទុកដាក់រៀបចំស្រះឲ្យបានត្រឹមត្រូវតាមបច្ចេកទេស
- ត្រីមេបាពូជត្រូវផ្លាស់ប្តូរបន្ទាប់ពីបានបង្កាត់២ទៅ៣ឆ្នាំ ហើយ ដើម្បីកុំឱ្យជាន់ឈាមគ្នា
- ប្រើអំបិល សេរ៉ូម និងអាល់កុលសម្រាប់សំអាតឧបករណ៍ និងសម្ភារៈ នៅក្រោយពេលប្រើប្រាស់
- ផ្តល់ចំណីឲ្យបានទៀងទាត់ ទាំងបរិមាណ និងគុណភាពចំណីល្អ
- ត្រូវរក្សាគុណភាពទឹកឱ្យបានល្អជាប់ជានិច្ច
- ឱ្យកសិករជីកស្រះបន្ថែម ដោយទាក់ទងក្រុមហ៊ុនជីកដីលក់ (កសិករបានស្រះឈ្នួញបានអាចម៍ដី)
- ចុះជួយណែនាំបច្ចេកទេសដល់កសិករ ដោយការអនុត្តន៍បច្ចេកទេសផ្ទាល់
- ផ្តល់វគ្គបណ្តុះបណ្តាល ដល់កសិករផលិត និងជំរុញកសិករឲ្យចូលរួមវគ្គផ្សេងៗ
- ណែនាំកសិករបង្កើនការចិញ្ចឹមត្រី ដើម្បីទុកធ្វើពូជដោយខ្លួនឯង និងរកទិញត្រីមេបាពូជពីធម្មជាតិ

## 1.6. អ័រម៉ូន ថ្នាំ និងឱសថបុរាណ

### 1.6.1. *ការអនុវត្តល្អ*

- ឈ្មោះអ័រម៉ូនស៊ុបព្រីហ្វាក់ (ឬហៅថាប៊ូសឺរ៉ាលីន) មានប្រសិទ្ធភាពជម្រុញឲ្យត្រីជម្រុះពង១០០% (ក្នុងលក្ខខណ្ឌសមស្រប) ដោយប្រើលាយជាមួយម៉ូទីលីយ៉ូម និងសេរ៉ូម
- ត្រូវលាយអ័រម៉ូនស៊ុបព្រីហ្វាក់ជាមួយម៉ូទីលីយ៉ូម និងសេរ៉ូមឱ្យហើយស្រេច ដើម្បីងាយស្រួលប្រើប្រាស់
- ត្រូវរក្សាទុកអ័រម៉ូនស៊ុបព្រីហ្វាក់និងល្បាយស៊ុបព្រីហ្វាក់ដែលលាយហើយ នៅកន្លែងមានសីតុណ្ហភាពត្រជាក់ ដូចជានៅបាតអាង ឬបាតពាងមានទឹកត្រជាក់

- ត្រីមេបាពូជចាក់ល្បាយអ័រម៉ូនស៊ុបព្រីហ្វាក់ពី ៥ទៅ ២៥ មីក្រូក្រាម ក្នុងមួយគីឡូក្រាមត្រីមេបាពូជ (ត្រីឈ្មោលចាក់ពាក់កណ្តាលត្រីមេ)
- ប្រើប្រាស់ជីធម្មជាតិ ឬអ៊ីអិចអឹម ដើម្បីព្យាបាលជំងឺត្រី និងកែប្រែគុណភាពទឹក

### 1.6.2. *ការអនុវត្តមិនបានល្អ*

- កសិករមិនបានយល់ច្បាស់ពីផលអវិជ្ជមានរបស់អ័រម៉ូនស៊ុបព្រីហ្វាក់ នៅពេលប្រើលើសបរិមាណកំណត់
- កសិករខ្លះបានប្រើបរិមាណអ័រម៉ូនលើសកម្រិតកំណត់បច្ចេកទេស
- កសិករមិនទាន់យល់ច្បាស់ពីរបៀបលាយល្បាយអ័រម៉ូនស៊ុបព្រីហ្វាក់ជាមួយម៉ូទីលីយ៉ូម និងសេរ៉ូម
- មិនមានភាពស្ទាត់ជំនាញក្នុងការចាក់ថ្នាំត្រី បង្កឲ្យត្រីមានរបួស
- ការថែរក្សាអ័រម៉ូនមិនបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

### 1.6.3. *ដំណោះស្រាយ*

- មិនមានដំណោះស្រាយ

**សំនូមពរដោះស្រាយបន្ត**

- មន្ត្រីបច្ចេកទេសវារីវប្បកម្មបន្តណែនាំកសិករឱ្យចេះប្រើអ័រម៉ូនស៊ុបព្រីហ្វាក់ ទាំងរបៀបលាយ និងរបៀបប្រើប្រាស់ តាមកម្រិតបរិមាណបច្ចេកទេសត្រឹមត្រូវ
- ជួយផ្តល់អ័រម៉ូនប្រភេទផ្សេងៗទៀត ដើម្បីឲ្យកសិករចេះប្រើប្រាស់
- ណែនាំ និងបើកវគ្គបច្ចេកទេសបន្ថែមដល់កសិករ
- ប្រើប្រាស់អំបិល ២ទៅ៣គីឡូក្រាមក្នុងទឹក១០០លីត្រ សម្រាប់ព្យាបាលជំងឺត្រី និងបំបាត់ភាពពុល
- កាត់បន្ថយប្រើប្រាស់ថ្នាំគីមី ដើម្បីព្យាបាលជំងឺត្រី
- គួរសិក្សា និងរកឯកសារបន្ថែមពីរបៀបប្រើប្រាស់ និងឥទ្ធិពលរបស់ថ្នាំគីមី រួចយកទៅបណ្តុះបណ្តាលកសិករផលិត។

## 1.7. ពូជត្រី និងតម្រូវការទីផ្សារ

### 1.7.1. *ការអនុវត្តល្អ*

- កសិករខ្លះផលិតបានកូនត្រីឆ្ពិន ត្រីអណ្តែង ត្រីទីឡាព្យ៉ា ត្រីកាបសាមញ្ញ ត្រីកាបឥណ្ឌា មានគុណភាពល្អ និងទំហំកូនត្រីពូជមានពី ៣ទៅ៦ ស.ម ឆ្លើយតបនឹងទំហំបច្ចេកទេស
- ត្រីមេបាពូជមានគុណភាពល្អ មានទំហំធំសមស្របជាមួយអាយុ និងទំងន់ និងដោយគ្មានរបួសស្នាម
- ចេះថែបំប៉នត្រីមេបាពូជតាមបច្ចេកទេស ដើម្បីឱ្យត្រីមេបាពូជមានសុខភាពនិងមានគុណភាពល្អ។

### 1.7.2. *ការអនុវត្តមិនបានល្អ*

- កសិករខ្លះមានពូជត្រីអាចជាន់ឈាម ខ្វះការគ្រប់គ្រងល្អ គ្មានការត្រួតពិនិត្យ និងកំណត់ចំណាំមេបាណាជាពូជល្អ

- មិនបានជ្រើសរើសកូនត្រីពូជជំនាន់ក្រោយមានគុណភាពល្អ ទុកសម្រាប់ធ្វើមេបាពូជ
- គ្មានព័ត៌មានទីផ្សារតម្រូវការកូនត្រីពូជច្បាស់លាស់ និងមិនទាន់ចេះស្វែងរកទីផ្សារដោយខ្លួនឯង។

### 1.7.3. *ដំណោះស្រាយ*

- កសិករខ្លះបានជ្រើសរើសកូនត្រីពូជពីប្រភពផ្សេងៗគ្នា ឬរកពូជពីធម្មជាតិ ដែលមានគុណភាពល្អ ដើម្បីទុកធ្វើត្រីមេបាពូជល្អសម្រាប់ជំនាន់ក្រោយ
- បានទិញត្រីមេបាពូជមានគុណភាពល្អពីខេត្តផ្សេងៗ
- បានរៀបចំចងជាក្រុមបណ្តាញកសិករផលិតកូនត្រី និងបានទំនាក់ទំនងជាមួយអតិថិជន អង្គការនានា ដែលមកទិញកូនត្រី ដើម្បីសួរនាំពីព័ត៌មានពីទីផ្សារតម្រូវការកូនត្រីពូជ
- កសិករខ្លះបានជីកស្រះបំប៉នបន្ថែម និងមានហាប៉ាទុកបម្រុងសម្រាប់បំប៉នកូនត្រី។

**សំនូមពរដោះស្រាយបន្ត**

- ត្រូវបន្តជ្រើសរើសពូជត្រីពីប្រភពផ្សេងៗគ្នាដែលមានគុណភាពល្អ មកទុកធ្វើជាត្រីមេបាពូជ
- ទាំងកសិករ រដ្ឋបាលជលផល អង្គការជាដៃគូរអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធរួមគ្នាជួយសម្រប សម្រួលសិក្សា និងប្រមូលពត៌មានទីផ្សារតម្រូវការកូនត្រីពូជទាំងក្នុង និងជុំវិញខេត្ត
- ជម្រុញឲ្យកសិករផលិត រកទិញត្រីមេបាពូជដែលមានគុណភាពល្អឲ្យបានច្រើន និងច្រើនប្រភេទ
- កសិករត្រូវផលិតកូនត្រីមានគុណភាពល្អ ដើម្បីកសិករទិញយកទៅចិញ្ចឹមទទួលបានជោគជ័យ និង ងាយរកទីផ្សារលក់កូនត្រីបានល្អនៅឆ្នាំក្រោយៗទៀត
- ផ្តល់បច្ចេកទេសអំពីការថែបំប៉នត្រីមេបាពូជ និងកូនត្រីបន្ថែមទៀត
- សិក្សារកប្រភេទពូជត្រីផ្សេងៗទៀតដែលមានគុណភាពល្អ មកផលិតដើម្បីបំរើតម្រូវការទីផ្សារ។

## 1.8. ការបំប៉នកូនត្រី( បច្ចេកទេស ការគ្រប់គ្រង ពេលវេលា )

### 1.8.1. *ការអនុវត្តល្អ*

- កសិករខ្លះបានសំអាតស្រះផ្សាំកូនត្រីពូជ និងបង្កើតចំណីធម្មជាតិ តាមបទដ្ឋានបច្ចេកទេស
- ក្រោយពីកូនត្រីអស់អាហារបំរុង កសិករបានផ្តល់ចំណីមានគុណភាពល្អ ដូចជាពងទាចំអិនដោយយក ផ្នែកក្រហម និងថ្លើមជ្រូកឆ្អិនច្របាច់ឲ្យម៉្ងត់បញ្ចូលគ្នាឲ្យកូនត្រីស៊ី (លើកលែងពពួកប្រភេទត្រីស៊ីសាច់)
- រៀបចំស្រះបំប៉នកូនត្រីពូជឆ្លិនទទួលបាជោគជ័យ ដោយប្រើកំបោរសសម្លាប់មេរោគ ចាប់ត្រីកាចនិង ពពួកសត្វផ្សេងទៀតដែលស៊ីកូនត្រី បារកក់បាតស្រះ និងប្រើស្បៃច្រោះទឹកនៅពេលបង្ហូរទឹកចូលស្រះ ដើម្បីការពារកុំឱ្យមានសត្វប្លង់គុង ត្រីកាច ឬសត្វល្អិតចូលស្រះ
- យកស្បៃមកបាំងជុំវិញ និងគ្របពីលើស្រះបំប៉នកូនត្រី ដើម្បីការពារសត្វមកស៊ីបំផ្លាញកូនត្រី
- បានបំប៉នកូនត្រីក្នុងហាប៉ា និងក្នុងស្រះ ដោយដាក់កម្រិតចំនួនកូនត្រីបំប៉នសមស្របតាមបច្ចេកទេស
- បំប៉នកូនត្រីឱ្យមានទំហំធំពី ៥ទៅ ៦សង់ទីម៉ែត្រ ទើបចាប់លក់។

1.8.2. *ការអនុវត្តមិនបានល្អ*

- សំអាតស្រះផ្សាំកូនត្រីពូជមិនបានល្អ ដោយមិនបានប្រើកំបោរសសម្លាប់មេរោគ ចាប់ត្រីកាចនិងពពួកសត្វផ្សេងទៀតដែលស៊ីកូនត្រី បារភក់បាតស្រះ និងមិនបានប្រើស្បៃច្រោះទឹកនៅពេលបង្ហូរទឹកចូលស្រះដើម្បីការពារកុំឱ្យមានសត្វប្លង់តុង ត្រីកាច ឬសត្វល្អិតចូលស្រះ
- មិនបានផ្តល់ចំណីឱ្យកូនត្រីស៊ីបានគ្រប់គ្រាន់ ទាំងបរិមាណ និងគុណភាព និងមិនបានទៀតទាត់ពេលវេលា
- ពេលខ្លះដាក់ចំណីច្រើនពេក ធ្វើឱ្យទឹកស្អុយ និងខាតបង់ថវិកា
- កសិករថែបំប៉នកូនត្រីលាយឡំគ្នាជាមួយកូនត្រីដែលមានគុណភាពល្អ និងកូនត្រីគ្មានសុខភាពល្អ
- ដាក់កូនត្រីបំប៉នក្នុងស្រះនិងហាប៉ាមានចំនួនច្រើនពេក ធ្វើឱ្យកូនត្រីមិនធំ និងមានសុខភាពមិនល្អ
- ស្រះខ្លះមានទឹកតិចពេក ធ្វើឱ្យទឹកក្តៅបំប៉នកូនត្រីមិនបានល្អ
- ស្រះខ្លះមានជម្រៅជ្រៅពេក ពិបាកក្នុងការថែបំប៉នកូនត្រី និងពិបាកនៅពេលប្រមូលផលកូនត្រី
- ស្រះខ្លះមានគុណភាពទឹកមិនល្អ មានជាតិអាស៊ីតច្រើន ឬជាតិកំបោរច្រើន ដោយសារប្រភេទដីមិនល្អមានទឹកចេញពីក្រោមដី
- កសិករមិនអាចផលិតកូនត្រីពូជបានគ្រប់ចំនួន និងគ្រប់ប្រភេទកូនត្រីពូជតាមតម្រូវការទីផ្សារ
- ពេលលក់កូនត្រី កសិករមិនបានគិតពីសុខភាព និងគុណភាពកូនត្រីពូជ
- កសិករមិនបានបន្សាំកូនត្រីពូជ១ថ្ងៃ មុនពេលចាប់លក់ និងដឹកជញ្ជូន
- កសិករចាប់កូនត្រីលក់មានទំហំតូចៗ។

1.8.3. *ដំណោះស្រាយ*

- រៀបចំស្រះផ្សាំកូនត្រីពូជតាមបច្ចេកទេសដូចបានរៀបរាប់ខាងលើ
- ដាក់កូនត្រីថែបំប៉នទាំងបរិមាណឱ្យសមស្រប និងមានគុណភាពល្អ
- សមាជិកក្នុងគ្រួសារកសិករ ត្រូវឧស្សាហ៍ជួយត្រួតពិនិត្យមើលស្រះកូនត្រី ជួយផ្តល់ចំណីឱ្យបានទៀងទាត់ និងគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព
- លក់កូនត្រីមានទំហំធំតាមបច្ចេកទេសយ៉ាងហោចណាស់មានទំហំ ៥សង់ទីម៉ែត្រ។

**សំនូមពរដោះស្រាយបន្ត**

- កសិករត្រូវព្យាយាមសំអាតស្រះតាមបច្ចេកទេសនិងត្រូវឧស្សាហ៍ត្រួតពិនិត្យមើលការបំប៉នកូនត្រីរាល់ថ្ងៃ
- ណែនាំកសិករឲ្យផ្តល់ចំណីកូនត្រីមានគុណភាពល្អសមស្របតាមបច្ចេកទេស
- ផ្តល់បច្ចេកទេសបន្ថែមទៀត អំពីរបៀបថែបំប៉នកូនត្រីដើម្បីទទួលបានជោគជ័យ
- មន្ត្រីជំនាញចុះជួយណែនាំបច្ចេកទេសបន្តទៀត។

## 1.9. ការគ្រប់គ្រងចំណីកូនត្រី និងការផ្តល់ចំណី

### 1.9.1. *ការអនុវត្តល្អ*

- កសិករខ្លះបានផ្តល់ចំណីបំប៉នកូនត្រីតាមបច្ចេកទេស ទៀតទាត់ពេលវេលា មានគុណភាពល្អ និងបរិមាណចំណីគ្រប់គ្រាប់
- បានរក្សាទុកដាក់ចំណីត្រឹមត្រូវតាមកន្លែង
- កសិករខ្លះបានចំអិនចំណី និងផ្តល់ចំនីឲ្យកូនត្រីស៊ីដោយពូតដាក់ក្នុងកញ្ច្រែង
- ផ្តល់ចំណីពងទាស្ងោរ (យកផ្នែកក្រហម) ម៉្សៅទឹកដោះគោ ថ្លើមជ្រូក សណ្តែកសៀង និងម្សៅត្រីឱ្យកូនត្រីម្សៅស៊ីចំនួន៣ដងក្នុង១ថ្ងៃ។

### 1.9.2. *ការអនុវត្តមិនបានល្អ*

- កសិករមិនទាន់ចេះគណនារូបមន្តប្រូតេអ៊ីន ដើម្បីរៀបចំផ្សំចំណីដោយខ្លួនឯង
- កសិករផ្តល់ចំណីឱ្យកូនត្រីស៊ីមិនបានគិតពីកម្រិតប្រូតេអ៊ីន និងគុណភាពចំណី
- ទុកដាក់ចំណីមិនបានល្អត្រឹមត្រូវតាមបច្ចេកទេស ដូចជាទុកចំណីចោលហាលថ្ងៃ ឬមិនបានបិតគម្រប
- ផ្តល់ចំណីមិនបានត្រឹមត្រូវតាមបច្ចេកទេស
- កសិករមិនបានដឹងពីបរិមាណចំណីត្រូវដាក់អោយកូនត្រីស៊ី
- កសិករមិនទាន់យកចិត្តទុកដាក់ខ្លាំងចំពោះបញ្ហារៀបចំផ្សំចំណីដោយខ្លួនឯង។

### 1.9.3. *ដំណោះស្រាយ*

- មិនទាន់ដោះស្រាយបានល្អនៅឡើយ ពិតមែនកសិករទទួលបានចំណេះដឹងបច្ចេកទេសពីវគ្គបណ្តុះបណ្តាល ប៉ុន្តែកសិករខ្វះទុន ខ្វះថវិកា ដើម្បីរៀបចំផលិតចំណីផ្សំដោយខ្លួនឯង។ ទោះជាយ៉ាងណាក៏ដោយ មន្ត្រីបច្ចេកទេសវារីវប្បកម្មបានបន្តការផ្តល់ប្រឹក្សាបច្ចេកទេសជូនកសិករឲ្យផ្តល់ចំណីត្រឹមត្រូវតាមបច្ចេកទេស និងទៀងទាត់ពេលវេលា ។

#### សំនូមពរសម្រាប់ដោះស្រាយបន្ត

- បន្តផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសបន្ថែមដល់មន្ត្រី និងកសិករពីរបៀបផលិតចំណីដោយខ្លួនឯង និងរបៀបគណនាប្រូតេអ៊ីនចំណី
- បន្តជម្រុញការផលិតចំណីតាមរូបមន្ត ចំអិនចំណីឲ្យត្រីស៊ីសម្រាប់១ថ្ងៃៗ និងទុកដាក់ចំណីនៅកន្លែងស្ងួតមិនត្រូវពន្លឺ និងគ្របឲ្យបានត្រឹមត្រូវ។

## 1.10. ការគ្រប់គ្រងគុណភាពទឹក (ការត្រួតពិនិត្យ និង វិធីសាស្ត្រកែលម្អ)

### 1.10.1. *ការអនុវត្តល្អ*

- កសិករបានប្រើជីធម្មជាតិសរីរាង្គដាក់ក្នុងរណ្ដៅជី ដើម្បីបង្ហូរចូលស្រះធ្វើទឹកស្រះឱ្យមានពណ៌បៃតង
- កសិករចេះប្រើប្រាស់ចំណីសមស្របតាមបច្ចេកទេស ដើម្បីកុំឱ្យទឹកស្រះខូចគុណភាព
- ចេះពិនិត្យមើលគុណភាពទឹកស្រះ និងចេះកែលំអគុណភាពទឹកស្រះ
- កសិករចេះរៀបចំស្រះកែអំគុណភាពទឹកស្រះ
- នៅពេលទឹកស្រះល្អក់ កសិករបានប្រើកំបោរ ឬបូមទឹកចេញ និងបញ្ចូលទឹកស្អាតក្នុងស្រះវិញដោយប្រើតម្រងស្បៃច្រោះ ដើម្បីមិនឲ្យមានត្រីកាច ឬសត្វល្អិតចូលស្រះ
- មន្ត្រីបានចុះណែនាំកសិករពីរបៀបកែលំអគុណភាពទឹកស្រះ ចុះវាស់វែងសីតុណ្ហភាព pH និងបរិមាណអុកស៊ីសែនរលាយក្នុងទឹក។

### 1.10.2. *ការអនុវត្តមិនបានល្អ*

- កសិករខ្លះមិនទាន់ចេះពិនិត្យគុណភាពទឹកស្រះច្បាស់លាស់
- កសិករគ្មានឧបករណ៍វាស់គុណភាពនៅក្នុងទឹក គ្រាន់តែចេះមើលនឹងភ្នែកទទេ
- កសិករខ្លះមិនបានពិនិត្យគុណភាពទឹកស្រះ និងបន្ថែមជីជាប្រចាំ
- កសិករមិនទាន់យកចិត្តទុកដាក់ខ្លាំងចំពោះការប្រើប្រាស់ជីធម្មជាតិ ដើម្បីបង្កើនចំណីធម្មជាតិ ឬសត្វល្អិតប្លង់តុងក្នុងស្រះ។

### 1.10.3. *ដំណោះស្រាយ*

- ពន្យល់កសិករពីផលប្រយោជន៍នៃការប្រើប្រាស់ជីធម្មជាតិ ចំពោះស្រះចិញ្ចឹម និងបំប៉នកូនត្រី
- មានមន្ត្រីគម្រោងចុះជួយណែនាំកសិករឲ្យចេះប្រើប្រាស់ជីសរីរាង្គ និងកាត់បន្ថយការប្រើប្រាស់ជីគីមី

**សំនូមពរដោះស្រាយបន្ត**

- បណ្ដុះបណ្ដាលបច្ចេកទេសបន្ថែមដល់មន្ត្រី និងកសិករពីការគ្រប់គ្រង និងរបៀបកែលំអគុណភាពទឹក (រៀនអនុវត្តផ្ទាល់ពីរបៀបមើលពណ៌ទឹក គុណភាពទឹកស្រះ របៀបវាស់កម្រិតប៉េហាស បរិមាណរលាយអុកស៊ីសែន កម្រិតpH ក្នុងទឹកស្រះ។ល។
- កសិករគួរយកចិត្តទុកដាក់ពិនិត្យគុណភាពទឹកស្រះត្រីរាល់ថ្ងៃ និងឧស្សាហ៍បន្ថែមជីធម្មជាតិក្នុងរណ្ដៅជីរួចបង្ហូរចូលស្រះត្រី នៅពេលទឹកស្រះគ្មានពណ៌បៃតង
- ផ្ដល់ឧបករណ៍សម្ភារៈវាស់ និងពិនិត្យគុណភាពទឹក និងពន្យល់ពីរបៀបប្រើប្រាស់ឧបករណ៍។

# 1.11. ធាតុគីមីសម្រាប់ស្រះត្រី

## 1.11.1. *ការអនុវត្តល្អ*

- ជីអ៊ុយរេ និងជីដេអាបេ ជាប្រភេទជីគ្រាប់ អាចយកមកប្រើសម្រាប់កែកំអគុណភាពទឹកស្រះ ដោយកូរវាឲ្យរលាយគ្រាប់ក្នុងទឹកអស់ រួចបាចចូលស្រះ ដើម្បីបង្កើតចំណីធម្មជាតិ និងធ្វើឲ្យទឹកស្រះមានគុណភាពល្អ
- មុនលែងកូនត្រីចូលស្រះ ត្រូវរៀបចំស្រះឱ្យមានគុណភាពទឹកល្អ ដោយប្រើកំបោរសបាចនៅបាតស្រះ និងជើងទេរស្រះក្នុងបរិមាណពី៥-១០គ.ក្រ/១០០ម$^{២}$ចំពោះស្រះចាស់ និងបរិមាណពី១០-១៥គ.ក្រ/១០០ម$^{២}$ចំពោះស្រះថ្មី ដើម្បីសំលាប់មេរោគ និងកែលម្អទឹកស្រះ។

## 1.11.2. *ការអនុវត្តមិនបានល្អ*

- កសិករមិនសូវមានការយល់ដឹងអំពីសារៈប្រយោជន៍ និងរបៀបប្រើកំបោរស ក្នុងពេលរៀបចំស្រះ និងក្រោយពេលរៀបចំស្រះ
- កសិករមិនបានប្រើជីធម្មជាតិដាក់ស្រះត្រីឱ្យបានញឹកញាប់ ក្រោយពេលដាក់កូនត្រីចិញ្ចឹមដើម្បីកែលំអគុណភាពទឹកស្រះ
- ឬមិនចេះប្រើកំបោរស ដើម្បីការពារព្យាបាលជំងឺត្រី
- កសិករប្រើតែកំបោរសមួយមុខ មិនប្រើជីសរីរាង្គបន្ថែម។

## 1.11.3. *ដំណោះស្រាយ*

- បានទិញនិងប្រើប្រាស់កំបោរសដែលមានលក់នៅតាមទីផ្សារ តាមការណែនាំរបស់មន្ត្រីបច្ចេកទេស
- ណែនាំគាត់ឲ្យប្រើប្រាស់ជីសរីរាង្គ និងកាត់បន្ថយការប្រើជីគីមី។

**សំនូមពរដោះស្រាយបន្ត**

- បន្តបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករពីរបៀបការប្រើប្រាស់កំបោរ និងការប្រើប្រាស់ជីធម្មជាតិ
- កំណត់អត្តសញ្ញាណកំបោរស ការប្រើប្រាស់និងឥទ្ធិពលរបស់កំបោរស
- មន្ត្រីជំនាញបន្តចុះជួយណែនាំកសិករអំពីសារៈប្រយោជន៍កំបោរស និងឱ្យកសិករបានយល់ដឹងរបៀបការប្រើប្រាស់កំបោរស។

# 1.12. ជីសរីរាង្គ

## 1.12.1. *ការអនុវត្តល្អ*

- កសិករបានយល់ដឹងពីសារៈប្រយោជន៍នៃលាមកមាន់ ទា គោក្របី ជ្រូក និងដើមទន្ទ្រានខែត្រ ជាជីសរីរាង្គធម្មជាតិយ៉ាងសំខាន់សម្រាប់ដាក់ស្រះចិញ្ចឹមត្រី
- កសិករបានប្រើប្រាស់ជីសរីរាង្គធម្មជាតិទាំងអស់នេះ

#### 1.12.2. *ការអនុវត្តមិនបានល្អ*

- កសិករខ្លះមិនបានជីករណ្ដៅជី ឬរណ្ដៅជីបានជីកហើយ តែមិនបានប្រើប្រាស់ទុកវាទំនេរចោល
- កសិករមិនបានប្រមូល និងរក្សាទុកដាក់ជីធម្មជាតិបានត្រឹមត្រូវ
- មិនបានប្រើជីធម្មជាតិដាក់ស្រែះចិញ្ចឹមត្រី ធ្វើឱ្យស្រះត្រីគ្មានចំណីធម្មជាតិសម្រាប់ត្រី។

#### 1.12.3. *ដំណោះស្រាយ*

- បន្តការណែនាំ និងពន្យល់កសិករឱ្យប្រើជីសរីរាង្គធម្មជាតិ សម្រាប់ពេលរៀបចំស្រះ និងក្រោយពេលរៀបចំស្រះ
- ជីករណ្ដៅជី និងប្រើប្រាស់រណ្ដៅជីសម្រាប់ត្រាំជីសរីរាង្គធម្មជាតិ
- ចុះពិនិត្យកសិករពីការប្រើជីធម្មជាតិ និងការប្រើរណ្ដៅជីទាំងនេះ។

**សំនូមពរដោះស្រាយបន្ត**

- ត្រូវមានការណែនាំបន្ថែម និងចុះតាមដានពីការអនុវត្តតាមបច្ចេកទេសប្រើជីសរីរាង្គធម្មជាតិរបស់កសិករ
- គួរបង្ហូរទឹកជីសរីរាង្គធម្មជាតិពីរណ្ដៅជីបន្ថែមចូលក្នុងស្រះ នៅពេលណាទឹកស្រះគ្មានពណ៌បៃតង

## 1.13. ជីគីមី

#### 1.13.1. *ការអនុវត្តល្អ*

- មានការប្រើប្រាស់ប្រភេទជីគីមី អ៊ុយរេ និងដេអាប៉េ តិចតួច
- កសិករបានយល់ដឹងពីភាពមិនចាំបាច់នៃការប្រើប្រាស់ជីគីមី និងនាំឱ្យខាតបង់ថវិកា។

#### 1.13.2. *ការអនុវត្តមិនបានល្អ*

- កសិករមិនបានយល់ដឹងពីរបៀបប្រើជីគីមី អ៊ុយរ៉េ និងជីគីមីដេអាប៉េ សម្រាប់ដាក់ស្រះចិញ្ចឹមត្រី
- ពេលខ្លះប្រើជីគីមីច្រើនហួសកម្រិតបច្ចេកទេសកំនត់ ធ្វើឱ្យត្រីពុល និងងាប់
- កសិករខ្លះប្រើជីគីមីនិងជីធម្មជាតិបញ្ចូលគ្នា ធ្វើឱ្យបរិមាណជីប្រើប្រាស់ហួសកម្រិតកំណត់នាំឱ្យត្រីពុល និងងាប់។

#### 1.13.3. *ដំណោះស្រាយ*

- បន្តការណែនាំកសិករឱ្យយល់ច្បាស់ និងឈប់ប្រើប្រាស់ជីគីមី មកប្រើតែជីសរីរាង្គធម្មជាតិវិញ ព្រោះចំណេញថវិកា និងមានប្រសិទ្ធភាព។

**សំនូមពរដោះស្រាយបន្ត**

- ណែនាំ និងលើកទឹកចិត្តកសិករឱ្យប្រើតែជីសរីរាង្គធម្មជាតិវិញ
- ព្យាយាមពន្យល់កសិករពីភាពមិនចាំបាច់នៃការប្រើជីគីមី។

## 1.14. ការថែទុកដាក់កូនត្រី ដើម្បីវេចខ្ចប់ និងដឹកជញ្ជូន

### 1.14.1. *ការអនុវត្តល្អ*

- កូនត្រីម៉្យៅក្រោយពីអស់អាហារបំរុង និងថៃបំប៉នក្នុងអាងរយៈពេលខ្លីត្រូវប្រមូលចេញពីអាងភ្លាម ដោយប្រើថ្នងដងដាក់ក្នុងចានដែក ឬធុង យកទៅលែងចូលក្នុងស្រះដែលបានរៀបចំល្អត្រឹមត្រូវតាមបច្ចេកទេសហើយ និងត្រូវអនុវត្តនៅពេលព្រឹកត្រជាក់មានថ្ងៃរះ
- មិនត្រូវផ្តល់ចំណីឱ្យកូនត្រីស៊ីក្នុងរយៈពេល២៤ម៉ោង មុនពេលចាប់កូនត្រីលក់ប្រសិនបើកូនត្រីត្រូវដឹកជញ្ជូនផ្លូវឆ្ងាយ
- កូនត្រីត្រូវថែទុកដាក់ឱ្យបានល្អក្នុងអាង ឬហាប៉ាក្នុងរយៈពេលខ្លី ឬ១ទៅ២ថ្ងៃ ដោយប្រើខ្យល់ជំនួយ មុនពេលវេចខ្ចប់ចងដាក់ក្នុងថង់កូនត្រី ដើម្បីឱ្យកូនត្រីមានសុខភាពល្អក្នុងរយៈពេលដឹកជញ្ជូននិងក្រោយពេលលែងកូនត្រីចូលស្រះចិញ្ចឹមត្រីហើយ
- ការរាប់កូនត្រីត្រូវមានសម្ភារៈត្រឹមត្រូវ និងប្រើខ្យល់ជំនួយ
- ចំពោះការដឹកជញ្ជូនផ្លូវឆ្ងាយ កូនត្រីត្រូវវេចខ្ចប់ក្នុងថង់ប្លាស្ទិកដែលមានគុណភាពល្អមិនងាយរហែក និងចាំបាច់ត្រូវប្រើខ្យល់អ៊ុកស៊ីសែនបញ្ចូលក្នុងថង់
- ថង់ប្លាស្ទិកដែលមានទំហំបណ្តោយ ១០០សង់ទីម៉ែត្រ និងទទឹង៦០ សង់ទីម៉ែត្រ អាចដាក់កូនត្រីដែលមានទំហំ ៥សង់ទីម៉ែត្រចំនួនពី ៣០០ ទៅ ៥០០ក្បាលក្នុង ១ថង់ អាស្រ័យទៅនឹងចំងាយផ្លូវត្រូវដឹកជញ្ជូន
- ចំពោះកូនត្រីអណ្តែង អាចដឹកជញ្ជូនដោយប្រើកាដុងជ័រ ឬធុងចំហមាត់ មិនចាំបាច់បញ្ចូលខ្យល់អ៊ុកស៊ីសែន និងអាចដាក់បានចំនួនច្រើនក្បាលក្នុង១ធុង
- ទឹកដាក់ក្នុងថង់ ឬធុងដាក់កូនត្រី ចាំចាច់ជាទឹកស្អាតល្អ គ្មានជាតិពុល
- សំភារៈដឹកជញ្ជូនកូនត្រីត្រូវមានសំបកបាវ ឬការ៉ុងក្រណាត់ សម្រាប់ទ្រាប់ថង់កូនត្រីកុំឱ្យធ្លាយរហែក
- កូនត្រីទីឡាព្យ៉ា ត្រីប្រា និងត្រីអណ្តែង មិនអាចដាក់លាយគ្នាជាមួយប្រភេទត្រីឆ្ពិន និងប្រភេទត្រីកាបក្នុងថង់តែមួយបានទេ
- ត្រូវចងថង់កូនត្រីឱ្យជិត និងតឹងណែនល្អ ដើម្បីកុំឱ្យថង់កូនត្រីធ្លាយ ឬខ្ទះខ្យល់អ៊ុកស៊ីសែន
- ក្នុងពេលដឹកជញ្ជូន ត្រូវរក្សាថង់កូនត្រីឱ្យមានសីតុណ្ហភាពត្រជាក់ កុំដាក់ថង់កូនត្រីឱ្យចំនឹងកំដៅពន្លឺព្រះអាទិត្យ
- គួរដឹកជញ្ជូនកូនត្រីនៅពេលមេឃត្រជាក់ ឬពេលព្រឹកព្រលឹមត្រជាក់ ប៉ុន្តែចៀសវាងលែងកូនត្រីចូលស្រះនៅពេលមេឃជិតភ្លឺ ឬពេលយប់ ឬពេលមេឃកំពុងភ្លៀង និងកុំលែងកូនត្រីចូលក្នុងស្រះដែលមិនទាន់បានរៀបចំល្អនៅឡើយ
- ចំពោះការដឹកជញ្ជូនផ្លូវឆ្ងាយ គួរប្រើម៉ូតូ ឬឡាន
- ចំពោះការដឹកជញ្ជូនផ្លូវជិត អាចប្រើកង់ ឬដើរ រែក ទូលជាដើម។

### 1.14.2. *ការអនុវត្តមិនបានល្អ*

- ពេលខ្លះកសិករអូសចាប់កូនត្រីពីស្រះ វេចខ្ចប់លក់ឱ្យកសិករយកទៅចិញ្ចឹមភ្លាមៗ ដែលជាហេតុធ្វើឲ្យកូនត្រីមានងាប់ច្រើននៅពេលដឹកជញ្ជូន និងបន្ទាប់ពីលែងចូលស្រះហើយ
- ដាក់កូនត្រីក្នុងថង់ច្រើនពេក ឬទឹកដាក់ក្នុងថង់កូនត្រីមិនស្អាត ឬមានជាតិពុល ធ្វើឱ្យកូនត្រីពុល និងងាប់ នៅពេលដឹកជញ្ជូនផ្លូវឆ្ងាយ
- លក់កូនត្រីពូជឱ្យទៅកសិករចិញ្ចឹមមានទំហំធំមិនស្មើគ្នា ធ្វើឱ្យកូនត្រីចិញ្ចឹមលូតលាស់មិនបានធំធាត់ល្អតាមបច្ចេកទេស
- ដឹកជញ្ជូនកូនត្រីនៅពេលថ្ងៃកំពុងក្តៅ និងគ្មានសំភារៈ ឬមធ្យោបាយបន្ថយកំដៅ
- លែងកូនត្រីចូលក្នុងស្រះដែលមិនបានរៀបចំបានល្អ ឬលែងនៅពេលយប់
- អូសចាប់កូនត្រីមិនបានត្រឹមត្រូវតាមបច្ចេកទេស ធ្វើឱ្យកូនត្រីមានសុខភាពអន់
- សម្ភារៈវេចខ្ចប់កូនត្រីមិនទាន់ត្រឹមត្រូវតាមបច្ចេកទេស ដូចជាប្រើថង់ប្លាស្ទិកចាស់ៗដោយមិនបានលាងសំអាត
- ក្រោយពីវេចខ្ចប់កូនត្រីហើយ មិនបានលាងសំអាត និងទុកដាក់សម្ភារៈឲ្យបានត្រឹមត្រូវ
- ប្រើស្នប់សប់កង់បញ្ចូលក្នុងថង់កូនត្រីដែលមានជាតិប្រេងអាចមានឥទ្ធិពលដល់កូនត្រី

### 1.14.3. *ដំណោះស្រាយ*

- កសិករបានរែងកូនត្រីពូជលក់ឱ្យមានទំហំដូចគ្នា
- ប្រើខ្យល់អ៊ុកស៊ីសែនសម្រាប់ការដឹកជញ្ជូនកូនត្រីផ្លូវឆ្ងាយ
- បន្តការចុះណែនាំកសិករផលិតកូនត្រីបន្ថែម ពីបច្ចេកទេវេចខ្ចប់ និងដឹកជញ្ជូនកូនត្រី។

**សំនូមពរដោះស្រាយបន្ត**

- បន្តចុះណែនាំកសិករឱ្យអនុវត្តបច្ចេកទេសទុកដាក់ វេចខ្ចប់ និងដឹកជញ្ជូនកូនត្រីឱ្យបានត្រឹមត្រូវតាមបច្ចេកទេស និងចៀសវាងការអនុវត្តមិនបានល្អត្រឹមត្រូវកន្លងមក
- នៅពេលដឹកជញ្ជូនកូនត្រី ត្រូវទុកដាក់ដបខ្យល់អុកស៊ីសែនដោយប្រុងប្រយត្ន កុំឱ្យភ្លេចបិទវ៉ាន ដើម្បីចៀសវាងខ្យល់ឆ្លាយចេញវាអាចបណ្តាលឲ្យផ្ទុះបាន។ ជានិច្ចកាលត្រូវដាក់ដបបញ្ឈរឲ្យត្រង់ ហើយត្រូវបិទវ៉ានភ្លាមនៅពេលឈប់ប្រើ ដើម្បីការពារកុំឲ្យសំណើមចូលក្នុងដបអុកស៊ីសែន។
- មិនត្រូវឱ្យមានផលិតផលណាដែលមានជាតិប្រេង ដូចជាប្រេងរំអិលនិងខ្លាញ់នៅជាប់ជាមួយដបខ្យល់អុកស៊ីសែនឬនាឡិកាវាស់កម្រិតខ្យល់អុកស៊ីសែននោះទេ ព្រោះវាងាយធ្វើឱ្យផ្ទុះឆេះធុងខ្យល់អុកស៊ីសែននោះភ្លាម។

## 1.15. ការថែទាំនិងប្រើប្រាស់ឧបករណ៍ និងសម្ភារៈ

### 1.15.1. *ការអនុវត្តល្អ*

- កសិករបានថែរក្សាទុកដាក់ឧបករណ៍ សម្ភារៈបានល្អ ដូចជាធុងខ្យល់ ម៉ាស៊ីនខ្យល់ ដុំខ្យល់ អួនហាប៉ា ជញ្ជីង ធុងដាក់ចំណី
- ទុកដាក់អ័រម៉ូននៅបាតអាងដំកល់ទឹក ដែលមានសីតុណ្ហភាពត្រជាក់
- បានលាងសំអាតអាងបង្កាត់ភ្ញាស់ និងទុកដាក់ឧបករណ៍សំភារៈនៅកន្លែងស្ងួត មានខ្យល់ចេញចូលល្អ ក្រោមដំបូល ក្រោយពេលប្រើប្រាស់រួច។

### 1.15.2. *ការអនុវត្តមិនបានល្អ*

- ធុងខ្យល់អុកស៊ីសែនគ្មាននាឡិកាវាស់និងទប់កម្លាំងខ្យល់អុកស៊ីសែន
- កសិករខ្លះរក្សាទុកដាក់ឧបករណ៍សម្ភារៈមិនបានត្រឹមត្រូវបន្ទាប់ពីបានប្រើប្រាស់រួច
- មិនបានលាងសំអាតទុកដាក់ ឬប្រើស៊ីរ៉ាំង និងប្រើម្ជុលចាក់ត្រីដដែលៗ
- អួនអូសកូនត្រីមិនបានលាងសំអាត និងចងហាលថ្ងៃ ក្រោយពេលប្រើប្រាស់រួច
- កសិករខ្លះមិនបានទុកដាក់អ័រម៉ូនបានត្រឹមត្រូវតាមបច្ចេកទេស។

### 1.15.3. *ដំណោះស្រាយ*

- បន្តការណែនាំកសិករឱ្យទុកដាក់ថែរក្សាឧបករណ៍សម្ភារៈបានល្អត្រឹមត្រូវ ក្រោយពេលប្រើប្រាស់រួច និងត្រូវអនុវត្តឱ្យមានអនាម័យជាប់ជានិច្ច ដើម្បីចៀសវាងការកើតមានឡើងជំងឺឆ្លងផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ បើកសិករអនុវត្តមិនបានត្រឹមត្រូវបច្ចេកទេស ឬនៅពេលមានជំងឺឆ្លងពីខាងក្រៅ។

**សំនូមពរសម្រាប់ដោះស្រាយបន្ត**

- សំណូមពរបន្តអនុវត្តតាមការណែនាំខាងលើត្រង់ចំនុច ការអនុវត្តល្អ ដំណោះស្រាយ និងចៀសវាងរាល់សកម្មភាពការអនុវត្តមិនល្អដែលបានរៀបរាប់បញ្ជាក់ខាងលើ។

# ផ្នែកទី២៖ ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ

## 2.1. ការជ្រើសរើសទីតាំងស្រះ និងជីកស្រះ

### 2.1.1. *ការអនុវត្តល្អ*

- ត្រូវជ្រើសរើសទីតាំងជីកស្រះបានល្អដូចខាងក្រោម៖
    - o ទីវាលស្រឡះគ្មានដើមឈើធំៗ និងនៅក្បែរប្រភពទឹក
    - o មិនលិចទឹកនៅរដូវវស្សា
    - o ជាប្រភេទដីអាចរក្សាទឹកបាន ៦ខែ យ៉ាងតិច
    - o នៅក្បែរផ្ទះ ជិតផ្លូវ និងស្រែ
    - o ស្ថិតនៅឆ្ងាយពីតំបន់ថ្នាំពុលកសិកម្ម
- ត្រូវជីកស្រះឱ្យសមស្របតាមបច្ចេកទេសដូចខាងក្រោម៖
    - o ជីកស្រះឱ្យមានរាងចតុកោណកែង
    - o ជីកឱ្យមានជើងទេរ
    - o ជីកឱ្យមានជម្រៅសមស្រប
    - o គ្មានដើមឈើព័ទ្ធជុំវិញ
    - o ជិតស្រះនៅជិតផ្ទះងាយស្រួលគ្រប់គ្រង។

### 2.1.2. *ការអនុវត្តមិនបានល្អ*

- ជ្រើសរើសទីតាំងជីកស្រះមិនបានល្អដូចខាងក្រោម៖
    - o ទីតាំងងាយទទួលទឹកជំនន់
    - o ជាប្រភេទដីជ្រាបទឹក ឬជាប្រភេទដីចេញទឹកមានជាតិអាស៊ីត
    - o ជាតំបន់រាំងស្ងួត ពឹងផ្អែកតែលើទឹកភ្លៀង
    - o គ្មានទឹកគ្រប់គ្រាន់នៅរដូវប្រាំង
    - o ជាទីតាំងនៅឆ្ងាយ ឬគ្មានទីផ្សារលក់ត្រី
- កសិករជីកស្រះមិនបានសមស្របតាមបច្ចេកទេសដូចខាងក្រោម៖
    - o ជីកស្រះជ្រៅពេក និងគ្មានជើងទេរ
    - o ស្រះជីកនៅតាមជ្រលងភ្នំ និងនៅឆ្ងាយពីផ្ទះ
    - o ជីកស្រះមានដើមឈើព័ទ្ធជុំវិញ។កសិករមិនយល់ពីផលប្រយោជន៍នៃពន្លឺព្រះអាទិត្យ

### 2.1.3. *ដំណោះស្រាយ*

- រៀបចំលក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសទីតាំងជីកស្រះ
- ណែនាំកសិករជីកស្រះតាមបច្ចេកទេស មានជើងទេរ មានជម្រៅសមស្រប

- ធ្វើរបងដោយព័ទ្ធស្បៃហ៊ុំជុំវិញស្រះ
- កសិករអាចចិញ្ចឹមត្រីក្នុងស្រែដោយជីកប្រឡាយព័ទ្ធជុំវិញស្រែឬជីកកូនស្រះមួយ ដើម្បីជាជម្រកត្រី
- សង់រោងយាមជាប់ស្រះដើម្បីការពារត្រីដាក់ចិញ្ចឹម
- កាប់មែកឈើដែលបាំងពន្លឺថ្ងៃចូលស្រះ។

**សំនូមពរដោះស្រាយបន្ត**

- កសិករគួរជីកស្រះនៅជិតប្រភពទឹក មិនលិចទឹកនៅរដូវវស្សា និងជីកស្រះតាមបច្ចេកទេស
- ផ្សព្វផ្សាយ និងបង្រៀនកសិករអំពីការជ្រើសរើសទីតាំង ការចិញ្ចឹមត្រី និងការគ្រប់គ្រងស្រះ

## 2.2. ការសាងសង់ស្រះ និងភ្លឺស្រះ

### 2.2.1. *ការអនុវត្តល្អ*

- ស្រះត្រូវជីកមានរាងចតុកោណកែង និងមានជំរៅសមស្រប
- មានបង្ហូរបំពង់សម្រាប់បង្ហូរទឹកចេញ ចូលស្រះ
- ភ្លឺស្រះត្រូវបង្ហាប់ឱ្យបានរឹងមាំល្អ
- ស្រះត្រូវមានទំនប់ការពារព័ទ្ធជុំវិញស្រះ និងត្រូវដាំស្មៅសម្រាប់ការពារការហូរច្រោះពេលមានភ្លៀង និងមានដាំបន្លែផ្សេងៗនៅលើភ្លឺស្រះ(ស្លឹកគ្រៃ ម្ទេស ត្រប់.....)
- ស្រះគួរមានទំហំចាប់ពី១០០ម$^{២}$ឡើងទៅ និងមានជម្រៅពី ២ម-២,៥ ម ទៅតាមទំហំស្រះ
- ស្រះចិញ្ចឹមត្រីរបស់កសិករប្រហែល ៥០% មានលក្ខណៈសមស្របតាមបច្ចេកទេស ដូចជាស្រះមានភ្លឺ, មានជើងទេរ, មានបាតស្រះរាបស្មើ.....)

### 2.2.2. *ការអនុវត្តមិនបានល្អ*

- ស្រះខ្លះមិនមានរាងចតុកោណកែង និងគ្មានបង្ហូរបំពង់ទុយោសម្រាប់បង្ហូរទឹកចេញចូលផងដែរ
- ស្រះគ្មានភ្លឺពទ្ធ័ជុំវិញ ស្រះមានជើងទេរចោទ និងភ្លឺស្រះមិនសាងសង់តាមបច្ចេកទេសល្អនៅឡើយ ( ក្រុមហ៊ុនជីកយកដីធ្វើថ្នល់)
- ស្រះកសិករមានជម្រៅលើសពី២,៥ម និងមានទំហំតូចពេក
- បាតស្រះភាគច្រើនមិនទេរទៅជ្រុងម្ខាង និងសំបូរភក់ច្រើន ដោយសារជីកស្រះមិនបានល្អ។

### 2.2.3. *ដំណោះស្រាយ*

- កសិករត្រូវលើកភ្លឺស្រះព័ទ្ធជុំវិញឱ្យបានរឹងមាំ
- ត្រូវកែលំអជើងទេរស្រះដែលចោទ ដើម្បីការពារការហូរច្រោះ និងបាក់ដីចូលក្នុងស្រះ
- ស្តារភក់បាតស្រះចេញ ក្រោយពេលប្រមូលផលត្រីរួច
- បាតស្រះគួរកែលំអឲ្យទេរទៅជ្រុងម្ខាងនៃស្រះ។

**សំនូមពរដោះស្រាយបន្ត**

- មន្ត្រីបន្តចុះជួយណែនាំ ផ្សព្វផ្សាយ និងពន្យល់ដល់កសិករឱ្យជីកស្រះតាមបច្ចេកទេស ដោយជីកស្រះឱ្យមានជើងទេរ ស្តារភក់ លើកភ្លឺ ជីកបាតស្រះអោយទេរទៅជ្រុងម្ខាង

## 2.3. ការជ្រើសរើសកូនត្រីដាក់ចិញ្ចឹម

### 2.3.1. *ការអនុវត្តល្អ*

- ដាក់ចិញ្ចឹមកូនត្រីប្រភេទចំរុះ (ដូចជាត្រីឆ្ពិន ទីឡាព្យ៉ា កាបសាមញ្ញ កាបតណ្ហា និងកាបស) ដើម្បីកូនត្រីស៊ីចំណីធម្មជាតិចំរុះដែលមានក្នុងស្រះ ក្រោយពេលបានដាក់ជីហើយ
- ជាប្រភេទត្រីងាយស្រួលរកពូជមកចិញ្ចឹម ធន់នឹងជំងឺ និងលូតលាស់លឿន
- ជាប្រភេទត្រីស៊ីចំណីដែលអាចរកបាននៅក្នុងភូមិ
- ជាប្រភេទត្រីមានតម្លៃនៅទីផ្សារ
- កសិករដាក់កូនត្រីចិញ្ចឹមក្នុងបរិមាណពី ៤-៥ក្បាល/ម$^{២}$
- កសិករទទួលបានទិន្នផលត្រីខ្ពស់ (ពី៣០ទៅ៤០គ.ក្រក្នុង១០០ម$^{២}$)
- កូនត្រីអណ្តែងអាចចិញ្ចឹមក្នុងស្រះប្លាស្ទិក ឬអាង ក្នុងបរិមាណពី ៣០ ទៅ ៤០ក្បាល/ ១ម៉ែត្រការេ ដោយអាស្រ័យនឹងលទ្ធភាពរបស់កសិករ ដែលអាចរកទិញចំណីឲ្យត្រីអណ្តែងស៊ីបានគ្រប់គ្រាន់។

### 2.3.2. *ការអនុវត្តមិនបានល្អ*

- មិនសូវបានគិតអំពីចំនួនត្រីដាក់ចិញ្ចឹមក្នុង១ម៉ែត្រការេ។កសិករដាក់ចិញ្ចឹមចំនួនត្រីច្រើនក្បាល/ម$^{២}$
- មិនបានយល់ដឹងពីលក្ខណៈជីវសាស្រ្តរបស់ត្រីនីមួយៗ
- កសិករបានទិញកូនត្រីដាក់ចិញ្ចឹម មិនបានគិតពីគុណភាពកូនត្រីពូជ
- កូនត្រីខ្លះមានទំហំមិនស្មើគ្នា
- កសិករចង់ទិញកូនត្រីមានទំហំតូចដាក់ចិញ្ចឹម ព្រោះមានតម្លៃថោក។

### 2.3.3. *ដំណោះស្រាយ*

- ត្រូវទិញកូនត្រីដាក់ចិញ្ចឹមឱ្យមានទំហំនិងអាយុដូចគ្នា
- តាមដាននិងបង្ហាត់បង្ហាញកសិករឲ្យយល់ពីលក្ខណៈជីវសាស្រ្តត្រី
- យកចិត្តទុកដាក់ណែនាំកសិករឲ្យចេះកត់ត្រាព័ត៌មានសំខាន់ក្នុងបំពេញតារាង និងតាមដានសកម្មភាពការចិញ្ចឹមត្រី
- ណែនាំឱ្យកសិករផ្តល់ចំណីត្រីឱ្យមានប្រូតេអ៊ីន និងបរិមាណគ្រប់គ្រាន់។

**សំនូមពរដោះស្រាយបន្ត**

- ណែនាំកសិករពីកន្លែងលក់កូនត្រី ដែលមានគុណភាពល្អ
- ណែនាំកសិករទិញកូនត្រីឱ្យមានទំហំធំស្មើគ្នា
- បន្តផ្តល់វគ្គបណ្តុះបណ្តាលបន្ថែមដល់កសិករពីបច្ចេកទេសចិញ្ចឹមត្រី។

## 2.4. ទិដ្ឋានការការពារត្រីកាច និងទឹកជំនន់

### 2.4.1. *ការអនុវត្តល្អ*

- មុនពេលរៀបចំបូមទឹកសំអាតស្រះ កសិករត្រូវប្រើជ័រស្បៃមុង និងលើកទំនប់ឱ្យខ្ពស់ព័ទ្ធជុំវិញស្រះឱ្យបានរឹងមាំ ដើម្បីការពារសត្វ ត្រីកាចចូលស្រះ និងទឹកជំនន់លិចស្រះ
- កសិករត្រូវប្រើប្រាស់កំបោរសក្នុងបរិមាណពី៥-១០គ.ក្រ/ក្នុង១០០ម២ ចំពោះស្រះចាស់ និង បរិមាណពី១០-១៥គ.ក្រក្នុង១០០ម២ចំពោះស្រះថ្មី ដើម្បីសំលាប់មេរោគនិងចាប់សត្វ និងត្រីកាច
- បន្ទាប់ពីស្រះរៀបចំបានល្អ និងមានទឹកគ្រប់គ្រាន់ហើយ កសិកររៀបចំដាក់ត្រីភ្លាម
- ក្នុងករណីក្រោយពេលដាក់កូនត្រីចិញ្ចឹមហើយ បើសង្កេតឃើញមានត្រីកាច កសិករអាចប្រើសន្ទូច ឬបង្កៃ ដើម្បីស្ទូចចាប់វាចេញ
- តំបន់ខ្លះមានសំបូរសត្វស្លាប កសិករគួរប្រើមង សំណាញ់ ដាក់គ្របពីលើស្រះ ឱ្យផុតពីផ្ទៃស្រះ ដើម្បីទាក់ចាប់សត្វស្លាបទាំងនោះ
- រៀបចំបំពង់ទុយោសម្រាប់បង្ហូរទឹកចេញនៅពេលមានភ្លៀងធ្លាក់ខ្លាំង
- កសិករត្រូវឧស្សាហ៍សំអាតស្មៅ និងរុក្ខជាតិដុះជុំវិញស្រះ ដើម្បីការពារកុំឱ្យសត្វចង្រៃពួនសម្ងំ។

### 2.4.2. *ការអនុវត្តមិនបានល្អ*

- រៀបចំស្រះមិនបានល្អ បាចកំបោរតិចតួច ចាប់ត្រីកាចមិនអស់ចេញពីស្រះ រួចដាក់កូនត្រីចិញ្ចឹម
- កសិករពិបាករកទិញកំបោរសពីទីផ្សារ
- ភ្លីស្រះទាប កសិករមិនបានធ្វើរបងនិងបាំងស្បៃព័ទ្ធជុំវិញស្រះ
- កសិករខ្លះទិញស្បៃបាំង តែបាំងមិនបានជុំវិញស្រះ
- កសិករខ្លះមិនយកឈើ ឬ ឬស្សីដែលមានស្រាប់ក្នុងមូលដ្ឋានមកធ្វើរបាំងព័ទ្ធជុំវិញស្រះ
- កសិករមួយចំនួនប្រមូលផលត្រីមិនអស់ មិនបានបាចកំបោរ ឬស្រះមិនបានហាលថ្ងៃ ដែលជាហេតុនាំឲ្យកូនត្រីទើបដាក់ចិញ្ចឹមមានអត្រារស់ទាប។

### 2.4.3. *ដំណោះស្រាយ*

- កសិករបានប្រើសន្ទូច និងប្រើអួនគៀរចាប់សត្វ និងត្រីកាចចេញពីស្រះ
- តាមដានណែនាំ និងផ្តល់យោបល់កសិករតាមបច្ចេកទេស ដើម្បីការពារកុំឱ្យមានត្រីកាច សត្វចង្រៃ និងទឹកជំនន់លិចស្រះ
- បានព្យាយាមប្រើប្រាស់កំបោរសកំចាត់សត្វនិងត្រីកាច ប៉ុន្តែប្រើប្រាស់កំបោរមិនបានត្រឹមត្រូវតាមបច្ចេកទេស។

**សំនូមពរដោះស្រាយបន្ត**

- មន្ត្រីបន្តចុះជួយណែនាំជម្រុញឲ្យកសិកររៀបចំស្រះឱ្យបានល្អមុនពេលដាក់ត្រីចិញ្ចឹម
- ណែនាំកសិករធ្វើរបងព័ទ្ធជុំវិញស្រះ និងដាក់ស្បៃបាំងជុំវិញស្រះ ដើម្បីការពារត្រីចិញ្ចឹមចេញពីស្រះ និងការពារត្រីកាចចូលស្រះ
- ឧស្សាហ៍កាត់ស្មៅជុំវិញស្រះ
- បណ្តុះបណ្តាលកសិករពីវិធីការពារគ្រោះទឹកជំនន់ និងរបៀបគ្រប់គ្រងស្រះកុំឱ្យមានត្រីកាចចូល។

## 2.5. ទិដ្ឋានការ ការពារការហូរចូលធាតុគីមីនិងថ្នាំពុល

### 2.5.1. *ការអនុវត្តល្អ*

- ជីកស្រះឱ្យឆ្ងាយពីតំបន់កសិកម្ម
- លើកទំនប់ភ្លឺស្រះអោយខ្ពស់ និងរឹងមាំល្អ
- មិនប្រើប្រាស់ថ្នាំពុលកសិកម្មជុំវិញស្រះ ដែលងាយបង្កឲ្យពុលដល់ត្រីចិញ្ចឹមក្នុងស្រះ។

### 2.5.2. *ការអនុវត្តមិនបានល្អ*

- ស្រះខ្លះមានភ្លឺតែទាប មានសត្វចោះរន្ធ ឬរូង ដែលងាយឱ្យទឹកហូរចូល ឬឆ្លងកាត់បាន
- មានកសិករដទៃប្រើប្រាស់ថ្នាំពុលគីមីនៅក្បែរស្រះចិញ្ចឹមត្រី
- ឬមានប្រើថ្នាំកំចាត់ស្មៅក្នុងចំការដំឡូងមីនៅជិតស្រះ។

### 2.5.3. *ដំណោះស្រាយ*

- លើកភ្លឺស្រះឱ្យខ្ពស់ទប់ទឹកកុំឲ្យហូរចូលស្រះ និងពិនិត្យមើលរូងឬរន្ធសត្វកុំឲ្យទឹកហូរឆ្លងកាត់ចូលបាន។

**សំនូមពរសម្រាប់ដោះស្រាយបន្ត**

- គួរការពារ ឬជីកស្រះនៅឆ្ងាយពីចម្ការ ឬស្រែដែលមានប្រើថ្នាំពុលកសិកម្ម
- បន្តតាមដាន និងពន្យល់កសិករឱ្យចេះពីរបៀបរៀបចំ និងគ្រប់គ្រងស្រះ
- បន្តការផ្សព្វផ្សាយពីផលប៉ះពាល់ដល់អ្នកប្រើប្រាស់ថ្នាំពុល។

## 2.6. ការគ្រប់គ្រងគុណភាពទឹកស្រះ

### 2.6.1. *ការអនុវត្តល្អ*

- ប្រើប្រាស់ជីសរីរាង្គ ក្នុងរណ្តៅជី
- យល់ពីអត្ថប្រយោជន៍នៃការប្រើប្រាស់ជីនិងកំបោរសម្រាប់រៀបចំស្រះ និងក្រោយពេលដាក់កូនត្រីចិញ្ចឹម

- កសិករប្រើប្រាស់ជីសរីរាង្គក្នុងរណ្ដៅជី និងបង្ហូរចូលស្រះជាប់ជាប្រចាំ
- ប្រើប្រហុកខូចគុណភាពប្រមាណ៣-៤ខាំ លាយជាមួយជីអ៊ុយរ៉េ២-៣ខាំ ដើម្បីកែលំអគុណភាពទឹកស្រះ
- បង្ហូរទឹកស្អាតគ្មានជាតិពុលចូលស្រះ ដោយប្រើស្បៃចម្រោះ
- ប្រើប្រាស់ជី អ៊ីអិច អឹម ឬ អ៊ី អឹម ដើម្បីកែលំអគុណភាពទឹកស្រះ
- ដាំរុក្ខជាតិទឹក និងប្រើប្រាស់ចំប៉ើង ដើម្បីកែលំអគុណភាពទឹកស្រះ។

### 2.6.2. *ការអនុវត្តមិនបានល្អ*

កសិករខ្លះមិនបានអនុវត្តល្អ ចំពោះសកម្មភាពមួយចំនួនដូចខាងក្រោម៖

- មិននិយមប្រើប្រាស់ជីសរីរាង្គ, ប្រើតែជីគីមី ឬមិនដែលប្រើប្រាស់ជីក្នុងពេលចិញ្ចឹមត្រី
- មិនទាន់មានជីករណ្ដៅជី ឬធុងសម្រាប់ផលិតជីទឹក
- មានរណ្ដៅជី តែមិនសូវដាក់ជីបន្ថែមជាប្រចាំ
- មិនបានបាចកំបោរ និងដាក់ជីពេលរៀបចំស្រះ
- មិនរៀបចំលើកភ្លឺស្រះនិងស្រះមានជើងទេរចោទពេក
- ដាក់ជីលាមកសត្វផ្ទាល់ទៅក្នុងស្រះ ដោយមិនប្រើរណ្ដៅជី
- មិនទាន់ចេះពិនិត្យគុណភាពទឹកច្បាស់លាស់ និងពីបច្ចេកទេសកែប្រែគុណភាពទឹក
- ពេលដាក់ជីក្នុងស្រះដែលកំពុងខ្វះអុកស៊ីសែន
- គ្មានកំបោររស់លក់គ្រប់គ្រាន់ក្នុងទីផ្សារ
- កសិករមិនមានឧបករណ៍វាស់គុណភាពទឹក និងអ្នកផ្សេងទៀតគ្មានម៉ាស៊ីនបូមទឹក។

### 2.6.3. *ដំណោះស្រាយ*

- បានជម្រុញកសិករឲ្យជីករណ្ដៅជី
- កសិករបានស្នើមន្ត្រីខេត្តណែនាំទៅរកកន្លែងលក់កំបោរ និងសួរនាំបន្ថែមពីរបៀបប្រើប្រាស់កំបោរ
- មានមន្ត្រីគម្រោងចុះជួយវាស់គុណភាពទឹក និងណែនាំបន្ថែមដល់កសិករឱ្យចេះបង្កើនចំណីធម្មជាតិក្នុងស្រះ តាមរយៈដាក់ជីសរីរាង្គក្នុងរណ្ដៅជី។

**សំនូមពរដោះស្រាយបន្ត**

- មន្ត្រីចុះជួយណែនាំកសិករបន្ថែមពីរបៀបគ្រប់គ្រងគុណភាពទឹកស្រះឱ្យបានល្អ
- បន្តការផ្សព្វផ្សាយដល់កសិករពីបច្ចេកទេសរៀបចំស្រះ របៀបការប្រើប្រាស់ជីក្នុងរណ្ដៅជី និងការបង្ហូរទឹកជីចូលស្រះ ក្រោយពេលដាក់កូនត្រីចិញ្ចឹមហើយ
- បណ្ដុះបណ្ដាលបន្ថែមដល់មន្ត្រី និងកសិករពីបច្ចេកទេសគ្រប់គ្រងគុណភាពទឹកស្រះ (រៀនមើលពណ៌ទឹក របៀបប្រើឧបករណ៍វាស់ប៉េហាស វាស់សីតុណ្ហភាព វាស់កម្រិតរលាយអុកស៊ីសែនក្នុងទឹកស្រះ...)។

## 2.7. កត្តាដែលចូលរួមដល់ការរក្សាគុណភាពទឹកល្អ

### 2.7.1. *ការអនុវត្តល្អ*

- កត្តាធម្មជាតិ (មានពន្លឺថ្ងៃ ខ្យល់ធម្មជាតិគ្រប់គ្រាន់ ស្រះជាប្រភេទដីមានជីវជាតិ)
- កត្តាមនុស្ស (ជីកស្រះ រៀបចំស្រះ ចេះប្រើបរិមាណកំបោរ និងជីសរីរាង្គបានត្រឹមត្រូវតាមបច្ចេកទេស)
- ប្រើប្រាស់ទឹកស្អាត គ្មានជាតិពុល ប្រើតម្រងច្រោះទឹក និងប្រើទ្រនាប់ទ្រទឹកពេលបង្ហូរទឹកចូលស្រះ
- ផ្តល់ចំណីឱ្យត្រីក្នុងបរិមាណគ្រប់គ្រាន់ គ្មាននៅសល់ចំណីក្នុងស្រះត្រី ដោយដាក់ចំណីចំអិនក្នុងកញ្ច្រែង ដើម្បីងាយស្រួលពិនិត្យមើលបរិមាណចំណីត្រីស៊ី
- ដាំរុក្ខជាតិទឹកក្នុងស្រះ និងត្រូវសំអាតរុក្ខជាតិទឹកកុំឱ្យដុះលើសពីចំនួន ៣០%នៃផ្ទៃស្រះ
- ដាំស្មៅនៅលើភ្លឺនិងជើងទេរស្រះដើម្បីការពារការហូរច្រោះបាក់ដីដែលនាំឱ្យខូចគុណភាពទឹកស្រះ
- ដាក់ចិញ្ចឹមប្រភេទត្រីស៊ីចំណីស្រទាប់បាតក្នុងបរិមាណតិចតួច
- ធ្វើរបងព័ទ្ធជុំវិញស្រះការពារគោ ក្របី ចូលស្រះ។

### 2.7.2. *ការអនុវត្តមិនបានល្អ*

- មិនបានដាំស្មៅពីលើភ្លឺស្រះ ជីកស្រះមានជើងទេរចោតពេក នៅពេលមានភ្លៀងធ្លាក់ជាប់ៗគ្នាបណ្តាលឲ្យមានការហូរច្រោះដីពីភ្លឺស្រះចូលស្រះ ធ្វើឱ្យទឹកស្រះល្អក់ជាប់ជានិច្ច។ ពេលនោះដាក់ជីមិនមានប្រសិទ្ធភាព និងកម្រិតថ្លា ឬគុណភាពទឹកស្រះថយចុះ
- ជីកស្រះមិនបានត្រឹមត្រូវតាមបច្ចេកទេស
- ស្រះកសិករប្រមាណជា ៥០% គ្មានភ្លឺស្រះត្រឹមត្រូវ ធ្វើឱ្យទឹកស្រះល្អក់នៅពេលមានភ្លៀងធ្លាក់ស្រះមានរុក្ខជាតិទឹកច្រើនលើសពី ១/៣នៃផ្ទៃស្រះ
- ដាក់ជី ឬបង្ហូរទឹកជីចូលក្នុងស្រះច្រើនពេក ធ្វើឱ្យទឹកស្រះស្អុយ និងងាយធ្វើឱ្យត្រីពុលងាប់
- ដាក់ចិញ្ចឹមប្រភេទត្រីស៊ីចំណីស្រទាប់បាតក្នុងបរិមាណច្រើនពេកដែលបណ្តាលកខ្វក់ទឹក
- ស្រះមួយចំនួនមិនបានបាចកំបោរ និងបានប្រើជីសរីរាង្គ។

### 2.7.3. *ដំណោះស្រាយ*

- នាំកសិករទៅទស្សនៈកិច្ចសិក្សាមើលស្រះដែលមានគុណភាពទឹកល្អ ពន្យល់ប្រាប់ពីហេតុផលដែលធ្វើឱ្យគុណភាពទឹកក្រខ្វក់ និងរបៀបកែលំអគុណភាពទឹកស្រះ
- ផ្តល់បណ្តុះបណ្តាលដល់កសិករបន្ថែមអំពីការប្រើប្រាស់កំបោរ និងជីសរីរាង្គតាមបច្ចេកទេស។

**សំនូមពរដោះស្រាយបន្ត**

- ជួយបណ្តុះបណ្តាលបន្ថែមដល់កសិករអំពីការគ្រប់គ្រងគុណភាពទឹក និងកត្តាជះឥទ្ធិពលអាក្រក់របស់វាទៅលើការចិញ្ចឹមត្រី
- បន្តផ្តល់ប្រឹក្សាបច្ចេកទេសដល់កសិករអំពីការកែលំអគុណភាពទឹក។

## 2.8. កត្តាដែលជះឥទ្ធិពលដល់ការលូតលាស់ និងអត្រារស់ខ្ពស់

### 2.8.1. *ការអនុវត្តល្អ*

- ការជ្រើសរើសពូជត្រីដាក់ចិញ្ចឹម ត្រូវមានគុណភាពល្អ គ្មានស្នាមរបួស ឬដំបៅនៅលើដងខ្លួន និងមានទំហំធំល្អសម្រាប់ចិញ្ចឹម
- រៀបចំកូនត្រីបានល្អមុនពេលចាប់លក់ ឬដឹកជញ្ជូន
- ដឹកជញ្ជូនកូនត្រីបានល្អត្រឹមត្រូវតាមបច្ចេកទេស
- លែងកូនត្រីចូលស្រះតាមសម្រួល ដូចបច្ចេកទេសបានណែនាំ
- ដាក់កូនត្រីចិញ្ចឹមឱ្យមានទំហំប៉ុនគ្នា
- ដាក់កូនត្រីចិញ្ចឹមក្នុងបរិមាណសមស្របតាមបច្ចេកទេស និងតាមប្រភេទត្រីនីមួយៗ
- ផ្តល់ចំណីមានគុណភាពល្អ មានបរិមាណគ្រប់គ្រាន់ ផ្តល់ឱ្យស៊ីត្រូវកន្លែង និងឱ្យស៊ីទៀងទាត់ពេលវេលា
- រក្សាគុណភាពទឹកឱ្យនៅពណ៌បៃតងជានិច្ច ដោយដាក់ជីជាប់ជាប្រចាំ
- ការពារកុំឱ្យមាន ត្រីកាច សត្វចង្រៃ កង្កែប និងពស់ចូលស្រះ
- តាមដានសកម្មភាពស៊ីចំណីរបស់ត្រី តើវាស៊ីចំណីដោយសកម្ម ឬមិនចង់ស៊ីចំណី

### 2.8.2. *ការអនុវត្តមិនបានល្អ*

- កសិករមិនសូវបានគិតពីបរិមាណកូនត្រីត្រូវដាក់ចិញ្ចឹមក្នុងស្រះតាមបច្ចេកទេស
- កសិករមួយចំនួនចិញ្ចឹមត្រីតាមបែបយថាផលដោយមានការងាររវល់ច្រើន
- ផ្តល់ចំណីឱ្យត្រីស៊ីច្រើនសល់លើសសល់ និងមិនបានទៀតទាត់ពេលវេលា
- កសិករមួយចំនួនមិនបានប្រើប្រាស់ជីសរីរាង្គ ឬប្រើប្រាស់មិនបានត្រឹមត្រូវតាមបច្ចេកទេស
- ប្តូរទឹកថ្មីក្នុងស្រះចិញ្ចឹមត្រីរអណ្តែងខុសបច្ចេកទេស ធ្វើអោយត្រីស្រេ្តស និងងាប់។

### 2.8.3. *ដំណោះស្រាយ*

- ចេះតាមដានការផ្តល់ចំណីដល់ត្រី មិនឲ្យលើស និងបាត់បង់ក្នុងទឹក
- ណែនាំកសិករអោយប្រើប្រាស់ជីកំប៉ុស្តិ៍ទឹកបង្ហូរចូលស្រះដើម្បី បង្កើនចំណីធម្មជាតិក្នុងស្រះ។

**សំនូមពរដោះស្រាយបន្ត**

- ផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសបន្ថែមដល់កសិករ ដើម្បីឲ្យកសិករមានជំនាញច្បាស់លាស់
- មន្ត្រីបន្តចុះជួយណែនាំបច្ចេកទេសបន្ថែម។

## 2.9. ចំណីផ្សំដោយកសិករ

### 2.9.1. *ការអនុវត្តល្អ*

- កសិករផ្សំចំណីត្រីដោយប្រើវត្ថុធាតុដើមដែលមានក្នុងភូមិស្រាប់ដូចជាកន្ទក់ ចុងអង្ករ កូនត្រីល្អិតៗ កាកសណ្តែកសៀង ដំឡូង កាកសំណល់ផ្ទះបាយ ស្លឹករុក្ខជាតិត្រកួន ល្ពៅ ត្រឡាច ។ល។
- ចំអិនចំណីផ្សំទាំងនេះលាយបញ្ចូលគ្នាឱ្យត្រីស៊ី
- ចំពោះការចិញ្ចឹមត្រីអណ្តែងកសិករផ្តល់ចំណី មានជាតិសាច់និងដែលមានស្រាប់ក្នុងភូមិ ដូចជា កណ្តៀរ ជន្លេន ពងអង្រ្កង និង ពស់។ល។
- ត្រូវប្រើកញ្រ្ចែងសម្រាប់ដាក់ចំណីឱ្យត្រីស៊ីដើម្បីងាយស្រួលតាមដានចំណីមាននៅសល់ឬមិនសល់
- កសិករចំអិនចំណីផ្សំសម្រាប់ឱ្យត្រីស៊ីតែរយៈពេលមួយថ្ងៃម្តងៗ ដើម្បីកុំឱ្យចំណីសល់ខូចគុណភាព

### 2.9.2. *ការអនុវត្តមិនបានល្អ*

- កសិករមិនចេះផ្សំចំណីឱ្យមានកម្រិតប្រូតេអ៊ីនតាមការចង់បាន
- ផ្តល់ចំណីឲ្យត្រីស៊ីមិនបានគិតទៅតាមប្រភេទត្រី ទំហំត្រី និងបរិមាណត្រីដែលមានក្នុងស្រះ
- មិនបានដាក់ចំណីឲ្យត្រីស៊ីក្នុងកញ្រ្ចែង ឬស៊ុម
- បាចចំណីដោយផ្ទាល់ក្នុងស្រះ និងឲ្យចំណីប្តូរទីកន្លែងច្រើនកន្លែង
- ផ្តល់ចំណីឱ្យត្រីស៊ីច្រើនពេក នាំឱ្យចំណីសល់ ខាតបង់ថវិកា និងខូចគុណភាពទឹក
- ចម្អិនចំណីមិនខាប់ស្អិត នាំឱ្យចំណីបែកចូលក្នុងទឹក ខូចគុណភាពទឹក និងខាតបង់ថវិកា
- កសិករខ្លះមិនបានចំអិនចំណី
- មិនបានកែច្នៃកសិផលរបស់គាត់ធ្វើជាចំណីត្រី
- មានកសិករខ្លះផ្តល់ចំណីមិនទៀងទាត់
- ផ្តល់ចំណីត្រីផ្សំតែមួយប្រភេទ ដូចជាកន្ទក់ នាំឱ្យត្រីលូតលាស់មិនសូវបានល្អ
- មានវត្ថុធាតុដើមចំណីក្នុងស្រុក ប៉ុន្តែកសិករមិនបានទាញផលប្រយោជន៍ពីវាឡើយ
- កសិករខ្លះមិនបានចាប់អារម្មណ៍ឬគិតពីការចំណាយ ចំណូល និងចំណេញពីការចិញ្ចឹមត្រី។

### 2.9.3. *ដំណោះស្រាយ*

- បន្តណែនាំកសិករផ្តល់ចំណីឱ្យត្រីស៊ី ចំពោះប្រភេទចំណីដែលមានស្រាប់ក្នុងភូមិ ដូចជា កណ្តៀរ ចក ជន្លេន កន្ទក់ ចុងអង្ករ កូនត្រីល្អិតៗ កាកសណ្តែកសៀង ដំឡូង កាកសំណល់ផ្ទះបាយ ស្លឹករុក្ខជាតិត្រកួន ល្ពៅ ត្រឡាច ។ល។
- ពេលចុះតាមដានកសិករ មន្ត្រីពន្យល់បន្ថែមពីបរិមាណចំណីត្រូវផ្តល់ឱ្យត្រីស៊ី
- ណែនាំនិងពន្យល់ឲ្យកសិករចេះរកសមាសធាតុផ្សំចំណីដែលមានប្រូតេអ៊ីនខ្ពស់ដូចជា ចំណីមាន ជាតិសាច់ សណ្តែក សៀង ស្លឹកកន្ទំថេត ជន្លេន ។ល។
- កសិករបានកែលម្អការដាក់ចំណីនៅក្នុងស៊ុម ដោយមិនបាចពង្រាយពេញផ្ទៃស្រះ
- បន្តការណែនាំដល់កសិករពី ការផ្តល់ចំណី និងរបៀបរៀបចំចំណីផ្សំ។

**សំនូមពរដោះស្រាយបន្ត**

- បន្តផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសផ្សំចំណីដល់កសិករ
- ជម្រុញកសិករឱ្យចេះផ្សំចំណីដោយប្រើវត្ថុធាតុដើមដែលមានស្រាប់ក្នុងភូមិ និងត្រូវចំអិនចំណីឱ្យត្រីស៊ី ចៀសវាងការឱ្យត្រីស៊ីចំណីមិនបានចំអិន
- លើកទឹកចិត្តនិងជម្រុញកសិករឲ្យផ្តល់ចំណីត្រីប្រកបដោយសារធាតុចិញ្ចឹមនិងបរិមាណអាស្រ័យនឹងប្រភេទត្រីនីមួយៗ។

## 2.10. ចំណីគ្រាប់ និងការផ្តល់ចំណី

### 2.10.1. *ការអនុវត្តល្អ*

- មានកសិករតែមួយចំនួនតូចដែលមានលទ្ធភាពបានផ្តល់ចំណីគ្រាប់ឲ្យត្រីស៊ីក្នុង១ថ្ងៃ ២ដង។
- ចំណីគ្រាប់មានប្រូតេអ៊ីនសមស្របសម្រាប់ការចិញ្ចឹមត្រី ពិសេសត្រីអណ្តែង
- ចំណីគ្រាប់គួរត្រាំទឹកឲ្យរីកសិន រួចបាចឲ្យត្រីស៊ីចំនួន ២ដងក្នុង១ថ្ងៃ
- តាមដានការផ្តល់ចំណីគ្រាប់ឲ្យត្រីស៊ីគ្រប់ពេល កុំឱ្យមាននៅសល់ព្រោះចំណីគ្រាប់មានតម្លៃថ្លៃ
- កសិករខ្លះក្រៅពីការផ្តល់ចំណីគ្រាប់ឱ្យត្រីស៊ី ក៏បានផ្តល់ចំណីផ្សំបន្ថែមឱ្យត្រីស៊ីផងដែរ។

### 2.10.2. *ការអនុវត្តមិនបានល្អ*

- កសិករផ្តល់ចំណីឲ្យត្រីស៊ីមិនទៀងទាត់ពេលវេលានិងមិនគ្រប់គ្រាន់ ព្រោះចំណីគ្រាប់មានតម្លៃថ្លៃ
- កសិករខ្លះប្រើប្រាស់ចំណីគ្រាប់ច្រើនពេក ឬចិញ្ចឹមត្រីប្រើចំណីគ្រាប់សុទ្ធ មិនបានផ្តល់ចំណីបន្ថែមធ្វើឱ្យខាតបង់ថវិកា ចិញ្ចឹមត្រីមិនចំណេញ
- ជាទូទៅកសិករភាគច្រើនមិនដឹងពីពីគុណភាពចំណីគ្រាប់ ឬមិនដឹងពីកំរិតប្រូតេអ៊ីនក្នុងចំណីគ្រាប់
- ការផ្តល់ចំណីគ្រាប់ឱ្យត្រីស៊ីមិនគ្រប់គ្រាន់តាមចំនួនត្រីដាក់ចិញ្ចឹមសរុបក្នុងស្រះ។

### 2.10.3. *ដំណោះស្រាយ*

- កសិករខ្លះបានផ្តល់ចំណីគ្រាប់ត្រឹមត្រូវតាមបច្ចេកទេស និងមានប្រើចំណីផ្សំឱ្យត្រីស៊ីបន្ថែម
- ជម្រុញឲ្យកសិកររកចំណីដែលមាននៅក្នុងមូលដ្ឋាន ឬចំអិនចំណីផ្សំបន្ថែមឱ្យត្រីស៊ី
- មន្ត្រីបានពន្យល់កសិករឱ្យចេះពិនិត្យពីប្រភេទ គុណភាពចំណី និងទីកន្លែងលក់ចំណីដែលមានគុណភាពល្អ
- មន្ត្រីបានណែនាំកសិករឲ្យចេះរកចំណីបន្ថែមក្នុងមូលដ្ឋាន ជៀសវាងការចំណាយថវិកាច្រើនទិញតែចំណីគ្រាប់ឱ្យត្រីស៊ី។

**សំនូមពរដោះស្រាយបន្ត**

- ណែនាំកសិករប្រើប្រាស់ចំណីគ្រាប់ ដោយត្រូវបន្ថែមចំណីផ្សំឱ្យត្រីស៊ីផងដែរ ដើម្បីចិញ្ចឹមត្រីទទួលបានផលចំណេញ ព្រោះចំណីគ្រាប់មានតម្លៃថ្លៃ។

# 2.11. ការគ្រប់គ្រងចំណី និងរក្សាទុក(ចំណីផ្សំ)

### 2.11.1. *ការអនុវត្តល្អ*

- កសិករបានទុកដាក់ចំណីត្រី (កន្ទក់ ,ចុងអង្ករ, ..) ក្នុងការ៉ុងក្រោមផ្ទះមិនត្រូវភ្លៀង និងពន្លឺថ្ងៃ...
- ចំណីផ្សំត្រូវបានចម្អិនឲ្យត្រីស៊ីសម្រាប់តែមួយថ្ងៃៗ
- កសិករមានផែនការរកចំណីទុកដើម្បីផ្សំជាចំណីឲ្យត្រីស៊ី

### 2.11.2. *ការអនុវត្តមិនបានល្អ*

- កសិករមួយចំនួនតូចទុកដាក់ចំណី នៅកន្លែងមិនបានត្រឹមត្រូវ (ត្រូវទឹកភ្លៀង ត្រូវពន្លឺថ្ងៃ)
- មិនបានគ្របចំណីដែលចម្អិនរួច ទុកឱ្យរុយរោម
- កសិករមិនសូវមានការយល់ដឹងពីការពិនិត្យគុណភាពចំណី (ចំណីសល់មានគុណភាពមិនល្អ ឲ្យត្រីស៊ី...)
- សម្ភារៈចម្អិនចំណីខ្លះមិនបានលាងសំអាត នៅក្រោយនិងមុនពេលយកមកប្រើបន្តទៀត។

### 2.11.3. *ដំណោះស្រាយ*

- មន្ត្រីបានពន្យល់កសិករឲ្យចេះពិនិត្យគុណភាពចំណី ទាក់ទងជាមួយកសិករដើម្បីប្រាប់ពីព័ត៌មានច្បាស់លាស់ពីកន្លែងមានលក់ចំណីមានគុណភាពល្អ
- កសិករមួយចំនួនបានចំអិនចំណីឲ្យត្រីស៊ីសម្រាប់រយៈពេល១ថ្ងៃ និងបានសម្អាតសម្ភារៈចំអិនចំណីទុកសម្រាប់ប្រើប្រាស់បន្តនៅពេលក្រោយ
- ព្យាយាមពន្យល់កសិករឱ្យបានដឹងពីរបៀបគ្រប់គ្រងធនធានចំណី ដើម្បីឱ្យចំណីមានគុណភាពល្អ

**សំនូមពរដោះស្រាយបន្ត**

- ផ្សព្វផ្សាយដល់កសិករពីបច្ចេកទេសប្រើប្រាស់ចំណី និងការក្សាទុកដាក់ចំណីដើម្បីឱ្យចំណីមានគុណភាពល្អ។

# 2.12. ការប្រមូលផលត្រី

### 2.12.1. *ការអនុវត្តល្អ*

- កសិករបានប្រមូលផលត្រីរំលោះ ដោយចាប់ត្រីធ្វើម្ហូបប្រចាំថ្ងៃ ឬលក់ ដើម្បីឱ្យត្រីដែលនៅសល់មានគុណភាពល្អ
- ប្រមូលផលត្រីទាំងស្រុងដោយការបូមទឹកពង្រីង និងប្រើអួនកៀរចាប់ត្រី
- ប្រមូលផលត្រីនៅពេលថ្ងៃ មេឃត្រជាក់។

### 2.12.2. *ការអនុវត្តមិនបានល្អ*

- ទីតាំងខ្លះ ទឹកស្រះឆាប់រីង គ្មានប្រភពទឹកស្អាតដើម្បីផ្គត់ផ្គង់ទឹកក្នុងស្រះ ដូចនេះកសិករត្រូវបង្ខំចិត្តប្រមូលផលត្រី ទោះបីត្រីចិញ្ចឹមនៅមានទំហំតូចនៅឡើយ

- កសិករប្រមូលផលត្រី ចំពេលត្រីមានតម្លៃថោកនៅទីផ្សារ
- ឧស្សាហ៍បង់សំណាញ់ចាប់ត្រីច្រើនដងធ្វើឱ្យត្រីផ្អើលលែងស៊ីចំណី
- ពេលបូមទឹកពង្រឹងស្រះកសិករចុះកកូរទឹក ធ្វើអោយល្អក់ទឹកស្រះ ត្រីពុលឆាប់ងាប់
- ត្រីទីឡាព្យ៉ាកូនក្នុងស្រះច្រើនដង វាអាចជាន់ឈាម កសិករស្តាយទុកដាក់ចិញ្ចឹមបន្តនៅឆ្នាំក្រោយ
- ស្រះមួយចំនួនមានទឹកជ្រៅពេកពិបាកប្រមូលផលដោយគ្មានសម្ភារៈគ្រប់គ្រាន់ដើម្បីប្រមូលផល។

2.12.3. *ដំណោះស្រាយ*

- ណែនាំកសិករប្រមូលផលត្រីរំលោះសម្រាប់ទទួលទានក្នុងគ្រួសារ កាត់បន្ថយការចំណាយថវិកាទិញត្រីពីផ្សារ និងលក់ឲ្យអ្នកជិតខាងនៅក្នុងភូមិ។

**សំនួមពរដោះស្រាយបន្ត**

- ដាក់ត្រីចិញ្ចឹមនៅពេលស្រះមានទឹកគ្រប់គ្រាន់
- ពន្យល់កសិករឲ្យប្រមូលផលត្រី នៅពេលត្រីមានទំហំធំ  និងលក់នៅរដូវត្រីឡើងថ្លៃ
- ឬណែនាំកសិករឲ្យប្រមូលផលត្រីលក់ នៅពេលខ្យត់ត្រីធម្មជាតិ
- រដ្ឋបាលជលផល និងអាជ្ញាធរដែនដី ព្រមទាំងកសិករខ្លួនឯង ព្យាយាមរកទីផ្សារលក់ផលត្រីចិញ្ចឹមក្នុងភូមិ ។

## 2.13. ការទុកដាក់ផលិតផល ដឹកជញ្ជូននិងកែច្នៃ

2.13.1. *ការអនុវត្តល្អ*

- ផលត្រីដែលកសិករចិញ្ចឹមបាន គឺទុកសម្រាប់ផ្គត់ផ្គង់ក្នុងគ្រួសារ និងទុកលក់ខ្លះដើម្បីបង្កើនប្រាក់ចំណូលក្នុងគ្រួសារ
- កសិករបានយកផលត្រីនៅសល់ពីការហូប ទៅធ្វើផ្អក ប្រហុក ត្រីឆ្អើរ ប្រឡាក់ទុកហូបក្នុងរយៈពេលយូរ
- កសិករបានប្រមូលផលត្រី និងលក់នៅក្នុងភូមិ ដោយដឹកជញ្ជូនដោយម៉ូតូ ឬកង់
- កសិករខ្លះលក់ត្រីដោយប្រើថង់ច្រកឲ្យអ្នកទិញ ប្រើកញ្ច្រែងដាក់ត្រី ឬ កន្ត្រក។

2.13.2. *ការអនុវត្តមិនបានល្អ*

- កសិករកែច្នៃផលត្រីចិញ្ចឹមគ្មានបច្ចេកទេស និងគ្មានអនាម័យត្រឹមត្រូវ កែច្នៃតាមលក្ខណៈប្រពៃណី
- កសិករពុំមានសម្ភារៈសម្រាប់វេចខ្ចប់ត្រឹមត្រូវ។

2.13.3. *ដំណោះស្រាយ*

- កសិករតែងធ្វើការកែច្នៃផលត្រីតាមទំលាប់នៃគ្រួសារនីមួយៗ

**សំនួមពរដោះស្រាយបន្ត**

- ណែនាំកសិករឲ្យត្រៀមរៀបចំសំភារៈសម្រាប់ទុកដាក់ផលត្រី
- ណែនាំកសិករឲ្យប្រមូលផលត្រីនៅពេលមេឃត្រជាក់។

## 2.14. ការត្រៀមដាក់ត្រីចិញ្ចឹម នៅឆ្នាំក្រោយ

### 2.14.1. *ការអនុវត្តល្អ*

- ក្រោយពេលប្រមូលផលត្រីហើយ កសិករបានរៀបចំសំអាតស្រះ បារភក់ បាចកំបោរ ដាក់ជីចាប់ត្រីកាច ហាលស្រះ ....សម្រាប់ដាក់ត្រីចិញ្ចឹមនៅឆ្នាំក្រោយ
- កែលម្អទំនប់ព័ទ្ធជុំវិញស្រះត្រី
- បានត្រៀមថវិកាសម្រាប់ទិញកូនត្រីពូជដាក់ចិញ្ចឹមនៅឆ្នាំក្រោយ។

### 2.14.2. *ការអនុវត្តមិនបានល្អ*

- មិនបានត្រៀមថវិកាសម្រាប់ទិញកូនត្រីពូជដាក់ចិញ្ចឹមនៅឆ្នាំក្រោយ
- មិនបានរៀបចំស្រះបានល្អឡើងវិញ មុនពេលដាក់កូនត្រីចិញ្ចឹម
- មិនបានកំណត់ពីប្រភេទត្រីច្បាស់លាស់សម្រាប់ដាក់ចិញ្ចឹមនៅឆ្នាំក្រោយ
- កសិករខ្លះមិនដឹងថាកន្លែងណាមានកូនត្រីលក់សម្រាប់ទិញដាក់ចិញ្ចឹមនៅឆ្នាំក្រោយ
- កសិដ្ឋានផលិតកូនត្រីនៅឆ្ងាយពីកសិករចិញ្ចឹម (ត្រូវចំណាយសោហ៊ុយដឹកកូនត្រីអស់ច្រើន)
- មិនបានគិតពីការទិញកូនត្រីថ្មីដាក់ចិញ្ចឹម ព្រោះចង់ចិញ្ចឹមត្រីដែលនៅសល់។

### 2.14.3. *ដំណោះស្រាយ*

- កសិករខ្លះបានទាក់ទងជាមួយមន្ត្រីគម្រោង ដើម្បីរកទិញកូនត្រីដាក់ចិញ្ចឹម
- ផ្តល់បច្ចេកទេសរៀបចំស្រះដល់កសិករ និងណែនាំគាត់ឱ្យព័ទ្ធស្បៃជុំវិញស្រះ ដើម្បីការពារកុំឱ្យមានត្រីកាចចូលស្រះចិញ្ចឹមត្រី ក្រោយពេលស្រះបានរៀបចំល្អហើយ។

**សំនូមពរដោះស្រាយបន្ត**

- ជម្រុញឲ្យកសិករដាក់ត្រីចិញ្ចឹមនៅដើមរដូវ ពេលមានទឹកគ្រប់គ្រាន់
- ណែនាំកសិករពីកន្លែងមានលក់កូនត្រីដែលមានគុណភាពល្អ និងមានតម្លៃសមរម្យ។